Khmer Story Lovers

# ២

## កម្លោះឡិមឡម

សំណាញ់រាត្រីកាលបានរាតអំណាច មកបង់ក្រសោបក្តោបទឹកដីប្រាង្គប្រាសាទ ឱ្យទទួលយកភាពអន្ធការជាយូរក្រែលមកហើយ។នៅលើស្បែនភាល័យ ព្រះចន្ទ្ររាងមូលក្រឡង់ក៏បានបណ្តែតខ្លួនរះបំភ្លឺសត្តនិករ ដោយចាំងជះរស្មីច្រាលរន្ទាល ដូចកំពុងរំលេចលំអទីក្រុងសៀមរាប ឱ្យភ្លឺចិញ្ចាចចិញ្ចែង និងទទួលបានតែភាពសុខដុមរមនា ។

នៅរាត្រីថ្មើរណោះ ស្រទាប់ភ្ញៀវទេសចរជាតិ ក៏ដូចភ្ញៀវទេសចរបរទេស នៅតែដើរកម្សាន្តទៅមកជាហូរហែតាមដងវិថីនានា ។ សូម្បីនៅប្របផ្លូវក្បែរជាយទីប្រជុំជនក៏ឃើញអ្នកលក់ដូរនៅតែចែចបប្រែយ៉ាងអ៊ូអែជាមួយភ្ញៀវ ហើយផ្ទុះសំណើចក្អាកក្អាយមិនដាច់សំនូរឡើយ ។ យានយន្តតូចធំចេះតែធ្វើដំណើរច្រវែងច្រវាត់ពុំមានអាក់ខានអ្វីដែរ ។

ដោយឡែក នៅក្នុងភូមិគ្រឹះដ៏ស្កុកស្កម្ភមួយនាកណ្តាលទីក្រុងឯណោះវិញ ក៏មានសភាពខ្សៀវខ្សារ អ៊ឹកអធឹក ពេញទៅដោយសេចក្តីសោមនស្សរីករាយជាពន្លឹក ។ រលកសម្លេងចម្រៀងស្រាលស្រទន់លាន់រងំ បានហើរចេញពីឧបករណ៍តូរ្យតន្ត្រីមួយវង់ ដែលរៀបចំនៅក្បែនម្ខាងក្បែរទូរទស្សន៍មួយ ដោយលើកតម្កល់បញ្ឈរខ្ពស់ ហើយរូបភាពនៃបទចម្រៀងការ៉ាអូខេ ក៏បានអណ្តែតនៅលើអេក្រង់ទូរទស្សន៍ ។

ចាវ៉ះអង្គុយទល់មុខលិខិតជាមិត្តសម្លាញ់ ដោយលើកកែវស្រាក្រឡែងតិចៗបណ្តើរ រួចងាកសម្លឹងទៅមើលបទចម្រៀងការ៉ាអូខេ នៅលើអេក្រង់ទូរទស្សន៍បណ្តើរទាំងសើចកក្អៀក :

- យើងថ្ងៃនេះ ពិតជារាសីខ្ពស់ត្រដែតឡើងដល់ត្រួយចេកមាស មែនណាអាសម្លាញ់...! បើកុំតែឡានខូចនៅផ្សារស្តន់ ម្ល៉េះប្រហែលជាយើងគ្មានវាសនាបានជួបមគ្គុទ្ទេសក៍ក្រមុំដ៏ស្រស់ប្រិមប្រិយនោះទេ...! ថ្ងៃនេះ ហេងអស្ចារ្យហើយវ៉ើយ...!

លិខិតលើកចង្កឹះត្បៀតចាប់សាច់ក្លែមដាក់ចូលមាត់ រួចទំពាញ៉ាំ១ទាំងគ្រវីក្បាល :

- មនុស្សប្រុសឡិបឡប់ច្រឡេមច្រឡឹមស្អី ពូកែរករឿងជម្លោះជាមួយមនុស្សស្រីយ៉ាងនេះ...? អាមនុស្សសាំត្រប៉ែដំណើបលាយខ្សាយឯងនេះ យើងសូមខ្លាចហើយ...!

នរៈក្រេបស្រារួចទម្លាក់កែវចុះ ដោយញាក់ចិញ្ចើម :

- ដំណើបលាយខ្សាយស្អីអាលិខិត...? កម្លោះថ្កាល់ខូច ហើយសាច់ផ្អែមយ៉ាងនេះ ថាអន់ណាស់អ្វីរកស្រីស្អាតមកធ្វើជាប្រពន្ធមិនបាននោះ...? ញញឹមមួយខ្ទាច់ ស្រីស្អាតម៉ោព្រាត ម៉ោទាំងក្រមុំរូបស្រស់ឈ្មោះកញ្ញារ័តន៍នោះទៀតផង...! ហែស... ហែស... មែនទេអាសម្លាញ់...?

លិខិតពេបមាត់ ញាក់ស្មា ហើយលើកកែវស្រាមកកាន់ :

- អើ...! ម៉ោព្រាតហើយស្រីកំបាក់កំពុក ភ្នែកស្រឡេវ ដំណើរកែក្រាយជើងកែកនោះ...! ភ្នែកលលីមលលាម ហើយមាត់ដាចយ៉ាងហ្នឹង បើស្រីណាបានឯងធ្វើជាប្តី មុខតែចាប់ហែកឯងស៊ីទាំងរស់ពុំខានទេ...! យើងស្គាល់ក្រយៅឯងច្បាស់ណាស់អាកម្លោះថ្លើមយោល អណ្តាតពាំព្រីង...!

ថាវរៈលើកស្លាបព្រាដួសពោតលីងមកទំពាគ្រួប១ ហើយធ្វើភ្នែកព្រឹម១ :

- ឯងកុំប៉ិនបង្អាប់យើងពេក អាដុកទ័រត្បាញអាយ...! ឯងមើល៍ហ្ន៎... យប់នេះព្រះចន្ទ្រភ្នំពេញដ៏ស្រស់ផូរផង់ បានរះលើមេឃាសៀមរាបហើយណា...! ប្រហែលជាគូព្រេងពីព្រឹទ្ធរបស់យើងចាប់កំណើតហើយទេដឹង បានជាយើងស្រមៃឃើញមុខនាងស្រស់កំផ្លង់១នៅនឹងមុខយ៉ាងនេះ...! កញ្ញារ័តន៍អូន... អូនស្អាតណាស់...! ស្អាតណាស់ព្រះចន្ទ្រភ្នំពេញ...! មេឃាសៀមរាបបង លង់ទ្រនេសដោយសារមន្តស្នេហ៍សម្រស់អូនហើយ...! បងក្អាញ់ ចង់តែជម្លោះជាមួយអូនទៀតទេ...!



ឃើញថាវរៈនិយាយផង ធ្វើកាយវិការដោយលើកដៃមកឱបដើមទ្រូង រួចត្រដុសមកលើមុខមាត់របៀបទន់សីកប៉ប្លឹកបែបរាយមាយ ក្រមិចក្រមើមផងនោះ ធ្វើឱ្យលិខិតញ្ចេញញ្ចេញ សើចហ៊ាស១ :

- ហ្ន៎...! ខ្មោចស្នេហាលុកលុយហើយតើ...! សឹងតែមួយថ្ងៃទៅហើយនិយាយតែឈ្មោះនាងក្រមុំកញ្ញារ័តន៍នោះមិនភ្លេចសោះ...! មុខមើល៍តែរូបចម្លាក់ទ្វារបាលនៅប្រាសាទព្រះខាន់អញ្ចឹង កុំសង្ឃឹមថាមានភ័ព្វវាសនាបានកញ្ញារ័តន៍ធ្វើជាគូនោះ មិនខ្មះទេ អាជេះអើយ...!

- ទ្វារបាល...? ទ្វារបាលក៏ទ្វារបាលចុះ ឱ្យតែបានតាមការពារស្រីស្រស់ឈ្មោះកញ្ញារ័តន៍...! កញ្ញារ័តន៍មាសបងអើយ អូនស្អាតមិនចាញ់ព្រះចន្ទ្រនៅយប់នេះទេ...! មុខអូនស្រស់កំផ្លង់១ សាច់ទន់កំភើ១ ធ្វើឱ្យមេឃាបង ពភ្លឺពភ្លើអស់ហើយអូន...! បងគ្រឹត១ខ្លាំងណាស់កញ្ញារ័តន៍អូន...!

ថាវរៈនៅតែធ្វើកាយវិការទន់រឡាក់ដដែល ញ៉ាំងឱ្យចិត្តលិខិតរីតតែក្តៅក្រហាយ ហើយចាប់បានសណ្តែកដីមួយគ្រាប់ ក៏ផ្ទាត់មកចំមុខអ្នកកម្លោះឱ្យភ្ញាក់ ទើបរលាស់សម្តី :

- រឡិករឡក់ដូចទឹកកន្លះក្អមអញ្ចឹង កោតតែចេះលបស្រឡាញ់ស្រីកើតដែរ...! អាមនុស្សអស់កែ អស់ប៉ះប៉ូវឯងហ្នឹង យើងអស់ខ្យល់ឈប់ដើររកប្រពន្ធហើយវ៉ើយ...! យើងលែងយកខ្លួនទៅធានាទៀតហើយ...! ឯងនេះប្រឡាំប្រកូវ ឡិមឡុមពេកណាស់...!

លិខិតនិយាយរួច លើកកែវស្រាមកក្រេបក្អឹក១ ស្របពេលនរៈទាក់សម្តីមកវ៉ាវ :

- អូ១...! មិនពឹង១ឯងទៀតទេអាលិខិត...! ចន្ទ្រះនៅក្នុងដៃយើងហើយ បើយើងមិនស្រវាចាប់មកថ្នាក់ថ្នមទេ មានតែយើងនេះជាមនុស្សភ្លើ...! កញ្ញារ័តន៍អូន មានស្រមៃឃើញលោកតាប៉ិកម្លោះមុខមានមន្តស្នេហ៍ទេអូន...? ប្រហែលជាមន្តស្នេហ៍គ្រាដំបូងរបស់យើងទេដឹង បានជាទេវតាឱ្យបងបានជួបអូន...? ម្ចាស់ចិន្តាបងអើយ... ហឺ... ហឺ... អូនស្អាតណាស់...!

- យើងថ្ងង់ណាស់អាថាវរៈ...! ឡប់នឹងស្នេហាតែឯងចុះ កុំនាំយើងឱ្យឆ្កួតជាមួយទៀតនោះវ៉ិ...! អាសាំត្របែ៉ឡែ១នឹងរោគស្នេហា...! ឈើយ...! ឆ្អើមណាស់...!

បម្រុងតបតមកលិខិត ដែលកំពុងលើកដបស្រាចាក់ស្រាចូលកែវតូច រួចលើកកែវតូចចាក់ស្រាចូលកែវទឹកកក ហើយបន្តគាស់កំប៉ុងសូដាចាក់ចូលកែវស្រាលាយទឹកកក ទើបថាវរៈងាកទៅឃើញនាងកំភ្លាញជាអ្នកបម្រើ ដើរឡើងមកពីជាន់ខាងក្រោម ដោយទ្រចានផ្ទុកអាពីងបំពង និងចានមួយទៀតផ្ទុកឆាគល់ខាត់ណា ទាំងធ្វើមុខស្រស់ប៉ប្រិម ។

លិខិតវេក្បាល តាមការសម្លឹងរបស់នរៈ ទាំងសើចគ្រហាញ :

- ហ្អំ...! បងកំភ្លាញ ចេះផ្គាប់ផ្គុនណាស់តើ...! ចុះថាវរី ម៉ោពីញ៉ាំការគេហើយអ្ហីបង...?

នាងកំភ្លាញលើកចានម្ហូបក្លែមទាំងពីរ មកតម្រៀបតាមសម្រួលនៅលើតុ ទាំងបន្ទន់ខ្លួនបន្តិច ហាក់ខ្លាចរអែងចិត្តភ្ញៀវមកពីភ្នំពេញ :

- ចាំសអ្នកប្រុស...! អ្នកនាងមិនទាន់ម៉ោទេ...!

- អារី ថីបានយូរ មកពីនាងជ្រេញនឹងមុខឯងហ្នឹងណាលោកដុកទ័រកម្លោះ...!

ថាវរៈនិយាយផង លើកសត្វអាពីងមកកាន់ទំពាផ្ងាច់១ផង នាំឱ្យលិខិតសើចស្ងេញដាក់នាងកំភ្លាញ :

- បងកំភ្លាញឮទេ...? អាកម្លោះសម្បុរអាពីងនេះ ពូកែជៀមដាមដាក់ខ្ញុំណាស់...! មើល៍១ខ្ញុំសួរបងកំភ្លាញដូចជាឆោតទៅចុះ...! តើរាល់ថ្ងៃនេះ បងកំភ្លាញឯងមានធុញទ្រាន់នឹងសម្ដីត្របែ៉លតរបស់អាថាវរៈទេបង...? ឯខ្ញុំវិញមិនទាន់បានកន្លះថ្ងៃផងស្ដាប់សម្ដីអាត្របែ៉ដំណើបខ្មៅនេះឡើងសង្អៀរត្រចៀកទៅហើយ...!

នាងបម្រើធ្វើជារៀបឫកពាឱនគោរពមកនរៈបន្តិច ទើបងាកមកឆ្លើយជាមួយលិខិតទាំងនៅសើចញឹម១ :

- អត់មានអីផងហ្នឹង អ្នកប្រុស...! មនុស្សជានាដូចគេដូចឯងហ្នឹង...!

- មនុស្សជានា...? ប្រហែលជា ទើបមកពីស្រោចទឹកនៅវត្តព្រះឥន្ទ្រកោសីយ៍



ឬវត្តដំណាក់ ឬក៏វត្តអង្គាទេដឹង បានជាមិនទាន់ជាដាច់នូវរោគឆ្កួត សរសៃប្រសាទនោះ...! មែនទេបងកំភ្លាញ...?

លិខិតញោះសម្ដីបង្អាប់មកថាវរៈ ធ្វើឱ្យនាងបម្រើគ្រវីក្បាល :

- ចេះតែថាហើយ...! អ្នកប្រុសរក្សមិនដែលមានរោគឆ្កួតផងហ្នឹង...! គ្រាន់តែសរសៃប្រសាទចូនថ្ងៃខ្លះតែប៉ុណ្ណោះ...!

នាងកំភ្លាញរបូតវាចាទាំងមិនចាប់អារម្មណ៍ ធ្វើឱ្យថាវរៈបើកភ្នែកធំប៉ុនកាក់ប្រាំសេន ហើយលិខិតផ្ទុះសំណើច ទាំងយកដៃខ្ទប់សំបុកពោះ :

- មែន១...! យើងថាមែន១...! ឯងនេះបើមិនកើតរោគឆ្កួតទេ គឺកើតរោគសរសៃប្រសាទ...! ចំម៉ាច់តែម្ដងហើយអាកំហិល...!

នរៈព្រួសអាពីងចេញពីមាត់ ហើយខំកែសម្រួលសម្ដីនាងបម្រើទាំងធ្វើមុខក្រមូវ :

- ផ្ដេសផ្ដាសណាស់បងកំភ្លាញ...! រោគឆ្កួត និងរោគសរសៃប្រសាទហ្នឹងដូចគ្នាណាបងកំភ្លាញ...! យីអើ... មិនជួយកាន់ជើងគ្នាឯង បែរជារុញទូកឱ្យក្រឡាប់កណ្ដាលបារាយណ៍ទៅវិញ...! បងកំភ្លាញនេះ កាន់តែល្ងីល្ងើអន្ទាក់អន្ទិចឡើង១ហើយតើ...! ទៅ១ អញ្ជើញទៅជួយធ្វើការអ្នកម៉ាក់វិញចុះ...!

ស្របពេលនោះ សម្លេងស្រួយស្រេះដូចអំបុកស្រូវថ្មី បានបង្ហើរមកឃាត់ដំណើរនាងបម្រើឱ្យទច់ជំហានភ្លាម :

- កុំអាលទៅបងកំភ្លាញ...! បងឯងចាំមើលមុខកម្លោះម្ទិះតុប១ទាំងពីរហ្នឹងសិនទៅ សឹមទៅវិញបង...! កម្លោះម្ទិះតុប១ទាំងពីរហ្នឹង ឱ្យតែបានជួបមុខគ្នា ព្រលះអាការសាហាវឱ្យរហូត...! មើល៍មុខខ្មៅព្រមឹកដូចគេព្រលាំងម្រ័ក្សទៅហើយ នៅតែពព្រើតនឹងអាការសាហាវទៀត...! ម៉េចក៏ធ្វើមុខម្ទែត១ ជ្រេញសម្ដីអួនណាស់អ្ហីបងលិខិត...?

ថាវរីស្លៀករ៉ូបពណ៌ផ្កាត្របែកព្រៃចាស់ ហើយតុបតែងសក់ស្រស់ត្រចង់ ដោយអូសដំណើរដ៏ស្រស់ល្វតល្វន់ សមនឹងរូបកាយស្រស់សោភាកំពិលខ្លួនចូលមកឈរក្បែរលិខិតរួចលើកដៃញ៉ឹងត្រចៀកកម្លោះវេជ្ជបណ្ឌិត :

- កុំតែបានឡានបងរក្សខូចនៅស្ងួន់ ម្ល៉េះមុខកម្លោះពេទ្យទយហ្នឹង មិនម៉ោជាន់ដីសៀមរាបទេ...! ម៉េចបានបើកគ្លីនិកថ្មីស៊ីៗ ភ្លេចគូដណ្ដឹងអស់រលីងទៅហើយអ្វីកម្លោះពេទ្យទយ...? ឯអូនវិញ ទឹកបងស៊ុំតែនឹងទ្រាំមិនបានទៅហើយ គ្មានទឹកតែវិញអន្ទាក់អន្ទិចសោះ...! ស្អប់បងឯងណាស់...!

លិខិតធ្វើមុខសី បែបឈឺផ្សានៅត្រង់ដៃថាវរីកំពុងមូលស្លឹកត្រចៀក ហើយខំនិយាយទាំងសើចតិចៗ :

- សឹងតែរកពេលដេកមិនបានផង តើមានពេលឯណាមកនឹកមុខគូដណ្ដឹងនោះព្រះម្ចាស់ថ្លៃ...! ទម្រាំតែដល់ថ្ងៃការ ប្រហែលជាត្រចៀកបងដាច់ចេញពីក្បាលមិនខានបើកាចឆ្នាសអញ្ចឹង...!

ថាវរីទម្លាក់ដៃចុះ រួចទាញកៅអីមួយមកអង្គុយក្បែរគូដណ្ដឹង ។ តាមពិតទៅថាវរី និងលិខិត បានភ្ជាប់ពាក្យជាគូដណ្ដឹងជាមួយគ្នាជិតមួយឆ្នាំមកហើយៗថាវរីក៏មានមុខរបរមួយដ៏សមគួរ ដោយបើកហាងលក់គ្រឿងអនុស្សាវរីយ៍គ្រប់ប្រភេទដ៏ទំនើបវិចិត្រមួយ នៅក្បែរទីប្រជុំជនជិតតំបន់ទេសចរ ។ ប្រការដោយអ្នកទាំងពីរមិនទាន់រៀបការគឺដោយសារអ្នកទាំងពីរដឹងអក់ពេល ស្វែងយល់ចិត្តថ្លើមគ្នាឱ្យបានជ្រាលជ្រៅបន្តិច ហើយម្យ៉ាងទៀតចង់ពង្រឹងជំហរខ្លួនឯងឱ្យបានមាំមួន សម្រាប់ដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ។

ថាវរះដូសគល់ខាត់ណាមកទម្លាក់ចូលចាន ហើយគ្រវីក្បាល :

- ពួកឯងកុំអាលរៀបការមុនយើងនោះ...! យើងយំឡាំបាំមិនឱ្យរៀបការទេ...! ចាំយើងការមុនសិន សឹមពួកឯងរៀបការតាមក្រោយ...! ឮឬនៅ ក្រមុំកម្លោះចេកទុំ...?

ថាវរីញាក់មុខដាក់បងប្រុស រួចចាប់អាពីងបំពងដាក់ចូលចានលិខិត :

- ឈិះ...! ចាំសេះដុះស្នែង ត្រីអណ្ដែងដុះស្រកាចុះ សឹមបងរក្សឯងរៀបការ...! ញោមស្រីមិនអាចចាំបងរក្សឯងរៀបការមុនឡើយ...! កូនប្រុសឱ្យត្រឡាំង បែរជាឈ្មះឈ្នាន ឥតកោតញញើតជាមួយស្រីៗទៅវិញ...! ម៉្ងៃៗឮតែនិយាយដើមពីរឿងស្រីៗ...! នាងនោះខ្មៅក្រិតមុខច្របូញ...! នាងនោះរួញកន្ទើ កន្ទុញកខ្វី...! នាងនោះមាត់



សម្ញើញស្រលៀងភ្នែក...! អូៗ ម៉្ងៃៗរិះគន់តែស្រីៗទេ...! យ៉ាប់ណាស់បងរក្សឯងនេះ...! មើលមុខឯងស្មានតែទេវបុត្រ ចុះម៉ោពីឋានសួគ៌ា...! វ៉ក... ចង់ក្អួត...!

នាងកំភ្លាញឈរខ្ទប់មាត់សើច ធ្វើឱ្យថាវរះញាក់មុខដាក់ប្អូនស្រី :

- កុំនិយាយពួកក្រមុំប្រាំ មិនបានថ្នាំម៉ាឆ្នុកទាំងនោះ...! បងលេបមិនចូលទេអារី...!

ថាវរីបែរមកសម្លក់បងប្រុស ហាក់ខឹងសម្បារ :

- ថាស្រីៗទាំងនោះសុទ្ធតែក្រមុំប្រាំ មិនបានថ្នាំម៉ាឆ្នុក...! សមនឹងឈ្មោះកម្លោះមាត់ប្រហុកណាស់ មាត់បងរក្សឯងនេះ...! រើសអីក៏រើសម្ល៉េះៗ... ឱ.. កម្លោះមាត់គីង្គក់...!

លិខិតទំពាអាពីងបណ្ដើរ ឱនមកខ្សឹបដាក់ត្រចៀកថាវរីបណ្ដើរ ធ្វើឱ្យនាងក្រមុំសើចឃឹកទះដៃ :

- តែប៉ុណ្ណេះ អូនជិតបានក្បាលជ្រូកញ៉ាំហើយបងលិខិត...! ចេះលបស្រឡាញ់ស្រីដែរតើ បងប្រុសមាត់ដាចរបស់ខ្ញុំ...!

ឆោមស្រស់ចំអែចំអន់បងប្រុសទាំងសើចកក្អេក រួចងាកមកសម្លឹងនាងបម្រើទាំងបើកភ្នែកភ្ញាក់ :

- អីយ៉ាស់...! ស្មានតែបងកំភ្លាញទៅបាត់ហើយ...! មានអីនៅឈរសើចឱ្យគ្រហឹៗនៅទីនេះទៅវិញ...!

នាងកំភ្លាញសើចញឹមៗតបសម្ដីមកវិញ ទាំងលបសម្លឹងមុខថាវរះកំពុងលើកកែវស្រាមកក្រេប :

- បើអ្នកនាងមិនទាន់ឱ្យខ្ញុំទៅ ម្ដេចខ្ញុំនឹងហ៊ានទៅ...!

- បងកំភ្លាញទៅវិញចុះ...! បន្តិចទៀតយកផ្លែគូលែនម៉ោណា...!

ស្ដាប់សម្ដីថាវរីទាំងបោះចម្លើយ " ចាស " រួចទើបនាងបម្រើរំកិលជំហានចុះមកជាន់ខាងក្រោម ដោយផ្ទុកស្នាមញញឹមស្រស់ ។ ចំណែកអ្នកទាំងបី នៅជជែកគ្នាទាំងសើចកក្អឹកលាយជាមួយសំនួរចម្រៀងការ៉ាអូខេលាន់លឿយៗ ។

នៅពេលនាងកំភ្លាញដើរចុះមកដល់ជាន់ក្រោម រួចអួសជំហានចូលបន្ទប់ទទួលភ្ញៀវ ក៏បានឃើញលោកថាវីរិទ្ធិដែលស្លៀកសារុងសូត្រ ពាក់អាវយឺតវៀលក្លៀកពណ៌សកំពុងអង្គុយទទូលទានផ្លែគូលែនបណ្ដើរ មើលទូរទស្សន៍បណ្ដើរ ហើយអ្នកស្រីផល្គុនកំពុងអង្គុយសម្អិតសម្អាតរូបចម្លាក់នានា ទាំងងាកមកទស្សនាទូរទស្សន៍ផង ឱនឈ្ងោកមកបំពេញកិច្ចការផង ។

លុះឃើញនាងបម្រើដើរត្រុន១ចូលមក ទើបលោកថាវីរិទ្ធិធ្វើមុខស្រស់កំប្លឹមញញឹមពព្រាយ វាយសម្ដីមកកាន់ភរិយា :

- ហ្ន៎...! កំភ្លាញម៉ោហើយ...! ម៉ាក់វាឯងឈប់រអ៊ីរអ៊ូដាក់បងទៀតឬនៅហ្អា...?

អ្នកស្រីផល្គុនដែលមានទម្រង់មុខមាំ ស្ថិតក្នុងចរិតឆ្មើងឆ្មៃ ងាកមុខមកសម្លក់ស្វាមីបន្តិច ទើបលើករូបចម្លាក់អប្សរាមកផ្ដុំកម្ចាត់ល្អងធូលី ទាំងជ្រៀងភ្នែកមើលមកនាងកំភ្លាញដែលកំពុងទម្លាក់ខ្លួនអង្គុយក្បែរ ហើយនិយាយរអែរអូរ :

- កុំធ្វើការស៊ុកគ្រលុក ខ្ជីខ្ជា ឥតសណ្ដាប់ធ្នាប់ខ្លាំងពេកណាកំភ្លាញ...! គ្រាន់តែយកគ្រឿងក្លែមឡើងទៅលើ បាត់រាប់ម៉ោង...! ឯងនេះធ្វើការឱ្យស្មៀច ដំអក់ពេលខ្លាំងណាស់..! ម៉េច១ចង់ទៅរួមគុជាមួយកូនលិខិត និងកូនរក្សណាស់អ្ហី..? យីអើ កំភ្លាញនេះ...!

លោកថាវីរិទ្ធិមានឋានៈខ្ពង់ខ្ពស់ក្នុងតំណែងល្អមួយ ក្នុងជួររាជរដ្ឋាភិបាលប្រចាំនៅខេត្តសៀមរាបនេះ ។ ចំណែកអ្នកស្រីផល្គុន ជាស្ត្រីមេផ្ទះ និងជានិច្ចកាល អ្នកស្រីតែងតែរៀបចំរូបចម្លាក់ និងសម្ភារៈអនុស្សាវរីយ៍ផ្សេង១ សម្រាប់ឱ្យថាវីយកទៅលក់ដូរនៅក្នុងហាង ។

នាងបម្រើធ្វើមុខស្មើ ដោយលើករូបចម្លាក់នានាខិតទៅម្ខាង ធ្វើឱ្យអ្នកស្រីបន្តសម្ដី :

- ធ្វើការឱ្យរហ័សរហួនខ្លះទៅ កុំស៊ើក១ខ្លាំងពេក យើងមិនចូលចិត្តទេ...! ចុះឯងទៅស្ទើរតែរាប់ម៉ោងហ្នឹង មានបានដំណឹងអីខ្លះទេកំភ្លាញ...?

- ឮតែអ្នកប្រុសលិខិត បង្គាប់អ្នកប្រុសរក្សហ្នឹងម៉ាក់អ៊ំ...!



ឮប្រយោគនាងកំភ្លាញនិយាយទាំងស្ទាក់ស្ទើរនៅក្នុងចិត្ត អ្នកស្រីផល្គុនងំឡើងមុខសម្លក់ :

- រកសាច់ការមិនបានទេ ឯងនេះ...! យើងរហិតរហៃស្ទើរតែចង់ខ្យល់ចាប់ទៅហើយ...! ណេ៎ះ...! រៀបចំរូបចម្លាក់ទាំងអស់ហ្នឹង ឱ្យស្រួលបួលទៅ...! យើងសុំពេលទម្រេតខ្នងបន្តិច...!

បញ្ចប់សម្លេងអ្នកស្រីក្រោកពត់ចង្កេះ រួចដើរមកទម្លាក់ខ្លួនលើសាឡុងអង្គុយក្បែរស្វាមី ។ លោកថាវីរិទ្ធិហុចចង្កោមផ្លែគូលែនមកឱ្យភរិយា ទាំងជម្រុះវាចាបែបកំប្លែង :

- ប៉ូវផ្លែគូលែននេះទៅ បាត់ខ្យល់ចាប់ហើយ...! បើម៉ាក់វាឯងពិបាកចាប់ខ្យល់ចាំបងជួយចាប់ឱ្យក៏បាន...! ពិបាកស្អី ម៉ាត្រឹមតែខ្យល់ចាប់ ចាប់ខ្យល់នោះ...!

អ្នកស្រីច្រានដៃស្វាមីដែលកំពុងកាន់ចង្កោមផ្លែគូលែនចេញ ហើយទះស្មាលោកថាវីរិទ្ធិ ទាំងធ្វើភ្នែកក្រឡោត :

- កុំរឡេបដូចកូនរក្សនោះ...! ខ្ញុំធុញណាស់ប៉ាវា...!

លោកថាវីរិទ្ធិសើចហ៊ិះ១ទាំងខ្ជាក់គ្រាប់គូលែនចេញពីមាត់មកដាក់លើទូកដៃម្ខាង:

- កូន និងឪទៅហើយ តើឱ្យគាត់ដូចអ្នកណាទៅហ្អាម៉ាក់វា...? ប៉ុន្តែ តាំងតែល្បងកូនមកពីភ្នំពេញវិញ តើថ្ងៃនេះម៉ាក់វាឯង មានសង្កេតឃើញអាអន្ទ្រើសកូនយើងវាយ៉ាងម៉េចខ្លះទេហ្អា...?

អ្នកស្រីផល្គុនទម្រេតខ្លួនផ្ងារស្រទាងផ្អែកទៅក្រោយ ដោយស្រដីរញ៉ាំរញ៉ូវ :

- ចេះប្រើសម្ដីបានពីរោះណាស់លោកប្ដី...! ហៅកូនរក្សសុទ្ធតែពាក្យល្បងកូនអាអន្ទ្រើសកូនយើង...! បើឪ និងកូន ម្នាក់១ឱ្យរឡេបយ៉ាងនេះ ប្រហែលជាខ្ញុំឡប់សតិអស់ហើយមើល៍ទៅ...!

លោកប្រុសទម្លាក់គ្រាប់គូលែនចូលចាន រួចលើកកន្សែងមកជូតមាត់ ហើយលើកកែវទឹកមកក្រេបទាំងខ្ពុរមាត់ឮស្វូរក្រុល១ ទើបទម្លាក់កែវចុះដោយសើចស្រស់ដាក់ភរិយា:

- ពូកែរង៉ើរង៉ូវណាស់ម៉ាក់វានេះ...! បងខំសួរពីរឿងកូនរក្ស បែរជានិយាយពី

រឿងឯណាឯណីទៅវិញ...! បើបងសួរហើយមិនឆ្លើយ...! ខ្ជិលនិយាយ...! បងទៅសម្រាកហើយ...! ស្អែកបងប្រជុំផង...!

អ្នកស្រីឃើញស្វាមីបម្រុងក្រោកដើរចេញ ក៏ងើបអង្គុយ ហើយទាញដៃលោកប្រុសឱ្យអង្គុយចុះ ទាំងលើកដៃទះខ្នងថើៗ :

- ប៊ុនឌិកង៉ក់ មើលតែកូនក្មេង...! ខ្ញុំដឹងតែទាំងអស់ហ្នឹង...! កូនរក្សថ្ងៃនេះប្លែកណាស់ប៉ាវ៉ា...! នៅពេលមកដល់ផ្ទះភ្លាម កូនរក្សដើរច្រៀងលោតរាំទន្ទាំឱ្យរំពើន...! សូម្បីតែចូលបន្ទប់ទឹក ក៏រាំផងច្រៀងផង ដូចជាចម្លែកណាស់...! ហើយខ្ញុំឮតែពាក្យកញ្ញារ័តន៍មាសបងៗឱ្យរហូត...! តិចកើតរោគស្នេហា ឆ្កួតចិត្តនឹងស្រីនៅភ្នំពេញទេដឹង...?

លោកថាវីរិទ្ធិសើចរលាក់ដងខ្លួន ហើយខំនិយាយពន្យល់ភរិយា :

- ម៉ាក់វ៉ានេះ ពិតជាមិនដឹងអីមែន...! តាមកូនលិខិតប្រាប់បង កូនរក្សពិតជាឆ្កួតចិត្តត្បិតជាប់ស្នេហ៍នឹងនាងក្រមុំមត្តទ្ទេសក៍ទេសចរម្នាក់ ឈ្មោះកញ្ញារ័តន៍ណាម៉ាក់វ៉ា...! កូនរក្សជួបនាងភ្លែត ក៏មួរមាត់បត់ជុំដៃឈ្លោះប្រកែកជាមួយគ្នាភ្លាម...! ឈ្លោះគ្នាតាំងពីនៅផ្សារស្ដន់ រហូតនៅលើឡានទេសចរ...! ប្រើពាក្យសុទ្ធតែយាយប៊ុ តាប៊ុ កម្លោះថ្មើមយោល ក្រមុំម្ទេសទុំ កម្លោះពណិព្រីង រាជិនីឪម៉ាល់...! ពាក្យស្អីៗទេច្រើនណាស់...! ដល់ពេលបែកពីនាង កូនរក្សបែរជាឡប់សតិលួចស្រឡាញ់គេតែម្នាក់ឯង...!

អ្នកស្រីផល្គុនបើកភ្នែកធំ លាន់សម្ដី :

- កូនរក្សអញ្ចឹងផង...? ម្ង៉ៃៗឱ្យរអាររអូម និយាយដើមតែពីរឿងស្រីៗ...! ហើយពួកស្រីៗក៏រសីបរសៀបនិយាយរអេចរអូច តែពីរឿងកូនរក្សពូកែពេបជ្រាយដល់ពួកនាងៗ...! ថាពួកនាងៗទាំងនោះ គ្មានវ៉ាសនាកើយលើទ្រូងកម្លោះថ្កាល់ខួច មុខមានមន្តស្នេហ៍ដ៏សង្ហាសមជាកំពូលបុរសមហាអង្គរទេ...! ពួកនាងៗ ខឹងច្រឡោតសម្បើមណាស់...! ឱ...! អាកម្លោះមាត់ដាចនេះ ម៉េចក៏ចេះស្រឡាញ់ស្រីដែរហ្ន៎...? ចុះប៉ាវ៉ាមានបានឃើញនាងកញ្ញារ័តន៍នោះទេ ហ៎ាប៉ាវ៉ា...? តើនាងស្រស់ស្អាតប៉ុណ្ណាទៅ...?

- ឃើញខ្មោចសេះស្អី...! សូម្បីតែកូនលិខិតក៏មិនបានឃើញផង...! ប្រហែលជានាងក្រមុំរូបនោះស្រស់ស្អាតហើយ បានជាកូនរក្សលង់ទ្រនេសដូចក្របីបាក់នឹមទន់លោងអញ្ចឹង...!



លោកប្រុសខំស្រដីទាំងញាក់មុខ ធ្វើឱ្យអ្នកស្រីខ្ទប់មាត់សើច :

- មែន...! កូនយើងសម្បុរខ្មៅព្រិកដូចក្របីមែន...! សម្បុរកាត់ដូចប៉ាវ៉ាហ្នឹង...!

នាងកំភ្លាញឮពាក្យសាសងទាំងនេះ ក៏បែរមុខចេញហើយសើចឃឹកៗ ធ្វើឱ្យលោកថាវីរិទ្ធិញញោចស្មាហើយសម្លឹងមុខភរិយា រួចក៏សើចកក្អេកកក្អាយព្រមគ្នា ទាំងធ្វើភ្នែកស្លឺមើលទៅជណ្ដើរសម្រាប់ដើរឡើងទៅជាន់ខាងលើ ។

ប៉ុន្តែនៅលើភូមិគ្រឹះជាន់ខាងលើនោះ ចេះតែឮសម្លេងចម្រៀងការ៉ាអូខេ និងស្នូរសំណើចយ៉ាងរអាករអាយ ហើរមកលាន់រហ៊ឹមរងំបន្ត ដូចកំដររាត្រីមានព្រះចន្ទ្ររះពេញបូរមីណ៍នេះ ឱ្យកាន់តែសុខមនោរម្យ ។

ខ្យល់ជំនោររាត្រីកាលបក់រសាត់មកត្រជាក់រហឹម ដោយបញ្ជ្រៀតចូលតាមចន្លោះបង្អួចផ្ទះសំណាក់ ធ្វើឱ្យកញ្ញារ័តន៍កំពុងគេងនិទ្រាទាំងរសាប់រសល់ ដោយដៃម្ខាងមានកាន់សៀវភៅ " ឯកសារមហាបុរសខ្មែរ " ដែលជាព្រះរាជពង្សាវតារខ្មែរចម្លងតាមសាស្ត្រាស្លឹករឹត ហើយដៃម្ខាងទៀតបត់កែងសន្ទឹងមកកល់ទ្រាប់ក្បាលឱ្យបានខ្ពស់បន្តិច ។

ទំនងជារួយស្រពន់ស្រយង់ដៃ នាងក្រមុំក៏ទម្លាក់សៀវភៅមកទើលើផែនទ្រូងណែនក្បុំងើបព្រហើនគួរឱ្យគ្រឹត រួចក៏រុញសៀវភៅរំកិលចុះ ដោយបង្វិលខ្លួនគេងផ្អៀងទាំងធ្វើមុខស្រស់បំព្រង ហាក់រសាប់រសើបព្រឺស្ញើបដូចមានគេមកស្ទាបអង្អែលកន្ត្រាក់កន្ត្រើនពេញរាងកាយ ។ ឆោមស្រស់គេងសើចញឹមៗ ទាំងស្រៀវស្រើបតែម្នាក់ឯងដោយលាន់មាត់តិចៗ... " មើលសៀវភៅក៏មិនជំនក់អារម្មណ៍...! ធ្មេចភ្នែកសម្ងំគេងក៏មិនលក់...! យប់នេះម៉េចក៏ខ្ញុំរសេះរសោះ រាយមាយចម្លែកម្ល៉េះ...? ធ្មេចភ្នែកក៏ឃើញរូបគេ...! បើកភ្នែកក៏ឃើញរូបគេ...! គេហ្នឹង ម្ដេចក៏មានឥទ្ធិមន្តសណ្ដិវិញ្ញាណខ្ញុំខ្លាំងអញ្ចឹង...? ស្រមោលគេពួនលីបលក្នុងបេះដូងខ្ញុំឱ្យរហូត...! " ។

អស់ពីរអ៊ូតិចៗរួច ឆោមល្អក៏បង្វិលខ្លួនគេងផ្ងារ ដោយពន្លឺចក្ខុសម្លឹងទៅពិតាន

បន្ទប់ ហើយក៏គូចចិត្តកើនមមៃបន្ត... កម្លោះឡិមឡុមម្នាក់ហ្នឹង មាត់ខិលណាស់...! តវ៉ាជាមួយខ្ញុំគ្មានញញើតមាត់ទេ...! ប្រុសកំហូច ពូកែជម្លោះជាមួយស្រី១ណាស់...! ប្រមាថខ្ញុំសុទ្ធតែយាយប៉ិម្ចសទុំ រាជិនីឪម៉ាល់...! កម្លោះច្រឡឹម ឡេមឡឹម ភ្នែកដូចអាបហ្នឹងខូចមែនទែន...! ប៉ុន្តែកម្លោះហ្នឹងខ្មៅមែន តែខ្មៅស្រស់ ញញឹមថ្កាល់ខូច ស្ពាក់ធំ ទ្រូងក៏មាំ រាងក៏បាន...! សង្ហាណាស់តើកម្លោះថ្លើមយោល...! សម្ដីសម្ដៅគំរោះគំរើយដូចដឹងខ្ទះដងក៏ពិតមែន ប៉ុន្តែពីរោះគួរឱ្យក្នាញ់ គួរឱ្យចង់ស្ដាប់ ចង់កេះក្បៀវទៅវិញ...! ពន្លឺភ្នែកមុតណាស់ ហើយធ្មេញសស្គុសដូចគេកាត់តម្រឹម...! ទាស់តែសម្ដីវឡិបវឡុបឱ្យវឡាញ...! ក្បាលខូចម្ល៉េះកម្លោះពណិព្រឹង...! ទេ... ទេយ៉ាងម៉េចហ្នឹងខ្ញុំ...? ខ្ញុំម្ដេចក៏គិតមមើរវើរវាយមាយទៅលើគេហ្នឹងខ្លាំងម្ល៉េះ...? តិច១ខ្ញុំ... ខ្ញុំមានកូនចិត្តលបស្រឡាញ់គេវិញទេដឹង...? គេហ្នឹងមានឈ្មោះអ្វីទៅហ្ន៎...? សម្បុរខ្មៅដូចក្អែកអញ្ចឹងប្រហែលជាគេមានឈ្មោះអាខ្មៅ បងម៉ៅ បងព្រឹង ពូប្រូទេដឹង...? តិចលោឈ្មោះបងពីងទេមើល៍ទៅ បានជាកាន់ថង់សត្វអាពីង ចង់បង្អួតប្រាប់ឈ្មោះដល់ខ្ញុំផងក៏មិនដឹង...? អីយ៉ា... បងពីងព្រឹងខ្មៅ សម្បុរខ្មៅរលោងដូចតែគ្នា...! តែផ្កាស... ខ្ញុំ... ខ្ញុំពិតជាបិសាចស្នេហាទន្រ្ទានលុកលុយហើយតើ...! ។

បញ្ចប់សម្ដីទាំងភ្ញាក់ខ្លួន ស្រស់នវនាថក៏ស្ទុះក្រោកអង្គុយ ដោយធ្វើមុខមិងម៉ាំង ស្លីស្រឡាំងកាំង រួចក៏សើចកក្អឹក ទាំងគ្រវីក្បាលតិច១ហាក់ហួសក្នុងចិត្ត ហើយក៏បន្ទន់ខ្លួនប្រះគេងទាំងឡេះឡះ តប់ប្រមល់ ។ ខណៈនោះ ទូរស័ព្ទដៃក៏បន្លឺសម្លេងនៅលើតុ ទើបស្រីស្រស់ទងវងក្រោកអង្គុយសាជាថ្មី ហើយអង្អិលខ្លួនចុះពីលើគ្រែដើរមកលើកទូរស័ព្ទទាំងញាក់មាត់ ញោចស្មា :

- យ៉ាងម៉េចហើយកម្លោះផ្លែអាយ...? នៅទីណាហ្នឹង...?

កុសលកំពុងដើរកម្សាន្តជាមួយអ្នកទេសចរដទៃ នៅក្នុងសួនច្បារក្បែរព្រះរាជដំណាក់ ខាងមុខសណ្ឋាគារជាប់លំដាប់ថ្នាក់ ខំញញឹមរាយមន្តសម្រស់ :

- បងកំពុងដើរយកខ្យល់រំហើយចិត្តនៅសួនច្បារ...! អូនអត់ទាន់គេងទេអ្ហ៎...?



- គេងមិនលក់ទេ...! ប្រហែលជាប្លែកកន្លែងហើយបងកុសល...!

ស្រស់តរុណីដើរមកទម្លាក់ខ្លួននៅលើគ្រែ ធ្វើឱ្យកុសលឈរក្ដិចស្លឹកបុប្ផជាតិបណ្ដើរ បង្ហើរសម្ដីតាមទូរស័ព្ទមកវិញបណ្ដើរ :

- ប្រហែលជាអូនគេងមិនលក់ មកពីនឹកស្រមៃអាអន្ទិតខ្មៅគម្រាំងចែតនោះទេដឹង...? បើអញ្ចឹងមែន បងខកបំណងខ្លាំងណាស់...!

ឆោមឆវីខ្ទប់មាត់សើចឃឹក ហើយពេបមាត់ :

- ហ្នឹងចង់ប្រច័ណ្ឌអ្វី កម្លោះសក់ស្លូត...? អូនមានកូនចិត្តឯណា ទៅគេងនឹកកម្លោះខ្មៅសម្ទេញ សាំត្រប៉ែពូកែជម្លោះនោះ...! បើបងកុសលឯងសាំសិន ហើយត្រប៉ែឡែដូចគេម្នាក់ហ្នឹង អូនខឹង អូនស្អប់ណាស់...! អូនមិនចូលចិត្តប្រុសរពៀរពៃ ហើយពូកែពៀះពោះអញ្ចឹងទេ...!

កុសលឈរញាក់ចង្កេះសើចប៉ប្រិម ខំបន្លឹមវាចាបន្ត :

- សុំទោស១ស្រីស្រស់ ដំណើររំញៀងញ៉ង...! បងមិនប្រច័ណ្ឌទេ គ្រាន់តែបងនឹករព្វកអូនទៅវិញប៉ុណ្ណោះ...! ទើបតែបែកពីអូនមុននេះបន្តិចសោះ ម៉េចក៏បងនឹកស្រមៃដល់រូបអូនខ្លាំងម្ល៉េះ...? តាមការពិតទៅ បងមិនចង់ឃ្លាតពីអូនមួយវិនាទីណាឡើយ...! បងស្រឡាញ់អូនខ្លាំងណាស់កញ្ញារ័តន៍...!

នាងក្រមុំលើកដៃម្ខាងផាត់សំនុំសរសៃសក់ទម្លាក់ទៅប៉ប្រះស្មាម្ខាង ហើយដៃម្ខាងទៀតនៅតែកាន់ទូរស័ព្ទនិយាយមកកុសល ទាំងសើចញឹម១ :

- អូនសូមអរគុណហើយ ដែលបងខំស្រឡាញ់អូន...! អូនក៏គ្មានបំណែកបេះដូងណាសម្រាប់ប្រគល់ឱ្យបុរសដទៃដែរ...! សម្រាប់រូបបង អូនមិនទាន់ជឿចិត្តទាំងស្រុងទេ...! អូនសុំពេលវេលាមួយ សម្រាប់តាមដានអង្កេតបង...! ព្រោះសេចក្ដីស្រឡាញ់ មិនស្ថិតនៅលើបបូរមាត់នោះទេ គឺស្ថិតនៅលើចិត្តបេះដូង និងរាល់គ្រប់សកម្មភាព...! ឱកាសមាសមិនរំលងឆ្ងាយពីជីវិតបងទេ ប្រសិនបើបងតម្កល់ខ្លឹមស្នេហ៍ភក្ដីពិតប្រាកដនោះ...!

កុសលញញឹមកាន់តែស្រស់ ហាក់ក្លាយជាអ្នកឈ្នះលើសង្វៀនស្នេហាដ៏ផ្អែមស្និតៈ

- បងរំភើបចិត្តណាស់កញ្ញារ័តន៍អូន...! គ្រប់ដង្ហើមចេញចូលរបស់បង គឺមានស្រមោលអូនក្នុងបេះដូងបងជានិច្ច...! អូនជាម្ចាស់ក្សត្រីយ៍ដ៏តូចច្រឡឹងក្នុងជីវិតបង...! បងសង្ឃឹមថា អនុស្សាវរីយ៍ដ៏ស្រស់បំព្រងរបស់យើង នឹងរីកដុះដាលដ៏រហង់នៅលើទឹកដីអង្គរនេះ...! បងនឹងខិតខំប្រតិបត្តិតាមអូន មិនឱ្យទើសទាល់អ្វីឡើយ...! ឥទ្ធិពលស្នេហាបង មានទំហំដ៏ធំមហិមាសម្រាប់ជីវិតអូន...! អូនល្អគ្រប់ សម្រាប់បេះដូងដ៏សំគមរបស់បង...! បេះដូងបងសាងមកអំពីសាច់ និងឈាមដ៏បរិសុទ្ធណាកញ្ញារ័តន៍មាសបង...!

រ័តន៍នារីក្រហមមុខឡើងផ្ទូរ ដូចផ្លែមាក់ប្រេងទុំ ហើយញញឹមស្រស់បែបអឹមអៀមៈ

- ពូកែលើកដាក់ពាក្យសម្ដីណាស់...! អញ្ចឹងប៉ុណ្ណឹងបានហើយ...! អញ្ជើញបងដើរកម្សាន្តឱ្យសប្បាយចិត្តចុះ...! តែកុំអត់ងងុយយូរពេក ព្រោះស្អែកយើងត្រូវដើរទេសចរណ៍តាំងពីវង់តូច រហូតដល់វង់ធំហត់នឿយណាស់...! បើអត់មានអ្នកណាកាន់ចង្កូតឡាន អូនច្បាស់ជាមូលភ្លៅបងកុសលឯងឱ្យជាំណាណីហើយ...!

- ប្របាទទាន...! ទទួលបញ្ជាព្រះរាជិនីដួងចិត្ត...! អូនគេងទៅវិញចុះ បងឈប់រំខានអូនទៀតហើយ...!

នរៈបិទទូរស័ព្ទទាំងលោតកញ្ឆេងហាក់សប្បាយចិត្ត ធ្វើឱ្យអ្នកទេសចរនៅក្បែរនោះ នាំគ្នាខ្ទប់មាត់សើចកក្អាកកក្អាយ ។ ចំណែកស្រស់ពិសីក៏បិទទូរស័ព្ទ ហើយឈោងទម្លាក់មកលើខ្នងតុ ដោយរអ៊ូរទាំទាំងធ្វើមុខស្មើ... " តើឥទ្ធិពលស្នេហាយ៉ាងម៉េចទៅ...? ស្នេហាជាអ្វី...? ជីវិតគឺជាស្នេហា ឬក៏ស្នេហាជាជីវិត...? ចុះខ្ញុំ រស់ដើម្បីស្នេហា ឬក៏ស្នេហាដើម្បីរស់...? ខ្ញុំគិតមិនយល់ មិនស៊ីជម្រៅទេ...! គ្រាន់តែខ្ញុំដឹងថា មន្តស្នេហានេះមានអានុភាពខ្លាំងណាស់...! " ។

កំពុងបន្ទន់ខ្លួនប្រះគេង ហើយបិទភ្នែកសន្សឹមៗ ទូរស័ព្ទដៃក៏រោទិ៍សម្លេងសាឡើងវិញ ធ្វើឱ្យស្រស់មាណវីប្រឹងបើកភ្នែក ទាំងធ្វើមុខក្រញូវ ហើយត្រវីក្បាលរអ៊ូ...



" ពិតជាបងកុសលទៀតហើយ ធុញទ្រាន់ណាស់ខ្ញុំ...! ម៉ែ្ងៗគិតតែពីទូរស័ព្ទ គ្មានស្ដាយលុយកាក់ទិញកាតដាក់បញ្ចូលទូរស័ព្ទបន្តិចណាសោះ...! យ៉ាប់មែនបងកុសលនេះ...! " ។

រអ៊ូរង៉ូវៗតែឯងបណ្ដើរ ស្រស់កល្យាណីក៏ឈោងទាញទូរស័ព្ទមកចុចទទួលបណ្ដើររួចទម្លាក់ខ្លួនគេងផ្ងារស្រទាងនៅលើគ្រែ ៈ

- អាឡូ...! យ៉ាងម៉េចទៀតហើយ បងកុសល...?

ពូញាណដែលកំពុងនិយាយទូរស័ព្ទ ដោយអង្គុយក្បែរមីងលំអងនៅក្នុងបន្ទប់ធំទូលាយនៃផ្ទះក្បឿងម៉ូតចាស់បុរាណ ហើយពូញាណ និងមីងលំអងជាឪពុកម្ដាយបង្កើតរបស់កញ្ញារ័តន៍ ។ ពូញាណភ្ញាក់ខ្លួនព្រើត ហើយបើកភ្នែកធំងាកមកសើចគ្រហាញដាក់មីងលំអង ទាំងជម្រុះសម្លេងលាយស្នូរសំណើច ៈ

- បងកុសលស្អី ស្រីរ័តន៍...? ពុកណា... ពុកទូរស័ព្ទទៅកូនឯងហ្នឹង...!

នាងក្រមុំភ្ញោចខ្លួន ស្ទុះក្រោកអង្គុយ ទាំងអរកខិបកខុប ៈ

- ពុកទេ...? សុំទោសពុក...! ខ្ញុំ... ខ្ញុំ...

បុរសជាឪពុកសើចលើកទឹកចិត្តបុត្រី រួចបែរមកសើចញឹមៗដាក់ភរិយា ៈ

- កុំភ័យអីស្រីរ័តន៍...! ពុកស្គាល់កុសលច្បាស់ទេតើ...! កុសលល្អនឹងកូនខ្លាំងណាស់...! ថ្ងៃនេះជាថ្ងៃទីមួយហើយដែលកូនបែកពីផ្ទះ ហើយក៏ជាថ្ងៃទីមួយដែរ ដែលកូននាំភ្ញៀវទៅលេងសៀមរាប...! ពុក និងម៉ែកូនចេះតែបារម្ភ ចេះតែគិតដល់កូន...! ចុះនៅតាមផ្លូវ កូនមានធឹងធោង រង៉ាក់រង៉ើក រក៏ក្ដួចង្អោរពុលនឹងឡានទេកូន...?

ឆោមស្រស់អង្គីលខ្លួនចេញបន្តិច ដោយទម្លាក់ជើងសំយុងចុះពីលើគ្រែ ហើយយោលជើងតិចៗ ៈ

- អត់មានអីទេពុក...! ខ្ញុំអរគុណណាស់ ដែលពុក និងម៉ែព្រួយបារម្ភ...! ចុះសុខភាពម៉ែយ៉ាងម៉េចដែរពុក...?

ស្រស់រ័តន៍នារីបង្ហើរសំណួរសួរមកលោកឪពុក ទាំងធ្វើមុខក្រៀមស្រពោន ។ ពូញាណខំញញឹមក៏លៃងសម ទាំងបម្រុងហុចទូរស័ព្ទមកឱ្យមីងលំអង ៈ

- អញ្ចឹង កូនជួបនឹងម៉ែកូនចុះ...! ម៉ែកូនអង្គុយនៅក្បែរពុកទេកូន...! នែ៎ម៉ែវា និយាយជាមួយស្រីរតន៍ទៅ...! កូនខំសួររកម៉ែវាឯង...!

មីងលំអងទទួលទូរស័ព្ទពីដៃស្វាមីមកកាន់និយាយជាមួយកូនស្រី ក្នុងសភាពស្ងួមស្ងៀមស្ងាំង ហាក់ផ្ទុកជម្ងឺរីងរៃអ្វីម្យ៉ាងនៅក្នុងខ្លួន ។ ស្ត្រីជាម្ដាយខំញញឹមទាំងបបូរមាត់ស្ងួតក្រៀម ភ្នែករូងស្លក់ :

- យ៉ាងម៉េចហើយកូនរ័តន៍...! ពេលបែកពីផ្ទះ កូនមាននឹកពុកម៉ែ និងកូនកងទេកូន...?

ឆោមនារីខំញញឹមទាំងបង្ហាញភាពស្រពោន រីករាលដាលនៅលើផ្ទៃមុខ :

- នឹកសឹងអីម៉ែ...! ចុះអូនកង វាគេងហើយអ្ហីម៉ែ...?

មីងលំអងបំបែរក្បាលសម្លឹងទៅកូនប្រុស ដែលមានអាយុប្រមាណដប់ពីរឆ្នាំ កំពុងដេកក្រវៀនក្បែរសុនខមួយក្បាលសម្បុរផ្លែត្នោតទុំ ត្រចៀកបាក់ខ្លួប កន្ទុយវែងរោមសំពោង មាឌធំដំបង ឈ្មោះសុក្កូឡា រួចស្ត្រីក៏ងាកមកសម្លឹងមុខស្វាមី ទើបនិយាយទាំងសម្លេងស្អកស្អា :

- កូនកងគេងហើយៗអាសុក្កូឡា ក៏ដេកក្បែរកូនកងដែរ...!

កែវនរនាថញញឹមស្រស់បន្តិច ដោយពន្លឺភ្នែកសម្លឹងទៅបន្ទះបង្អួចកំពុងយោលអង្គីខ្ញើក១ ដែលខោកកកិតនឹងសម្ពាធខ្យល់រាត្រី :

- ចុះសុខភាពម៉ែ យ៉ាងម៉េចដែរនៅពេលនេះ...? ព្រោះម៉ែមានជម្ងឺត្រាំត្រែងជាយូរមកហើយ...! ជាពិសេស នៅពេលកូនចេញមកឆ្ងាយអញ្ចឹង ជម្ងឺម៉ែមិនដឹងជាយ៉ាងម៉េចទេ...!

- ស្រីរតន៍កូនកុំបារម្ភអី...! បើម៉ែមិនស្រួល ពុកកូននឹងទូរស័ព្ទទៅកូនភ្លាម...! សៀមរាប ភ្នំពេញ មានឆ្ងាយឯណា...! ចង់ផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស កូនអាចវិលមកផ្ទះវិញបានយ៉ាងឆាប់រហ័ស...! ចុះកុសលគេទៅណាហើយកូន...?

មីងលំអងនៅតែប្រឹងសួរដេញដោលរកកុសល ទាំងខំសើចមិនសូវស្រស់ដាក់បុរស



ជាប្ដី នាំឱ្យនាងក្រមុំសើចប៉ប្រិម :

- បងកុសលទើបតែទូរស័ព្ទមកខ្ញុំអម្បាញ់មិញ...! គាត់ប្រាប់ថា ដើរកម្សាន្តយក៏ខ្យល់អាកាស...!

ស្ត្រីសើចស្ងើ ហាក់មានរឿងរ៉ាវជំពាក់វាក់វិននៅក្នុងចិត្ត :

- ជិតមួយឆ្នាំមកនេះ កុសលគេធ្វើអំពើល្អមកលើគ្រួសារយើងជាច្រើន...! ម៉ែ និងពុកចេះតែលបពិគ្រោះគ្នាថាកុសលជាក្មេងល្អ ឬកពាស្លូតបូតត្រឹមត្រូវគួរឱ្យរាប់ គាប់នឹងភ្នែកញាតិណាស់...! កូនបានការងារនេះធ្វើ ក៏ដោយសារកុសល ជាពិសេសជួយបង្ហាត់បង្ហាញគ្រប់បែបយ៉ាង...! កុសលជាមនុស្សតស៊ូក្នុងសង្គម មានតែម្ដាយចាស់បួសជាដូនជី កាន់ធម៌កាន់អាចិសំណាក់នៅនឹងវត្ត ផ្ញើខ្លួននឹងម្លប់ព្រះពុទ្ធសាសនា...! ម៉ែ និងពុកពេញចិត្តពេញថ្លើមនឹងកុសលខ្លាំងណាស់...!

ពូញាណងក់ក្បាលផ្ងក់១ ដូចរំភើបចិត្តនឹងសម្ដីភរិយា ធ្វើឱ្យមីងលំអងខំស្រដីមួយ១បន្ត :

- កូនធំល្មមនឹងមានគូស្រករហើយ...! ពុក និងម៉ែមើលកុសលពិតជាមិនខុសទេ...! ម៉ែមានជម្ងឺជាប្រចាំ...! ម៉្ងៃកាត់ម៉្ងៃកោរ ហើយម៉ែក៏ចង់ឃើញកូនមានប្ដីសីក្រាបផ្ទឹមសំពះក្បាលដល់កន្ទេលជាមួយកុសល...! បើម៉ែយ៉ាងម៉េចយ៉ាងម៉ាទៅ ក៏បានឮភ្លេងការរបស់កូន និងកុសលដែរ...! ស្រីរតន៍ កូនមានឮម៉ែនិយាយទេកូន...?

កែវកល្យាណីប្រែទឹកមុខសញ្ជប់សញ្ជឹង ប្រឹងពិចារណាតាមរលកសម្ដីមាតា លុះឮប្រយោគសំណួរម្ដាយ ឆោមឆវីក៏សើច ដោយឆ្លើយតបទៅវិញនូវភាពពាក្យពេចន៍ស្រាលស្រទន់ :

- ឮតើម៉ែ...! ប៉ុន្តែបញ្ហានេះ កូនសុំពេលគិតឱ្យល្អិតល្អន់បន្តិចសិន...! ការចាប់ដៃគ្នាសាងជីវិតជាគូភរិយាស្វាមីនឹងគ្នា មិនមែនសម្រាប់តែមួយថ្ងៃ ឬមួយឆ្នាំនោះទេ គឺសម្រាប់ពេលយូរអង្វែង ជាពិសេសត្រូវតាមដាន និងសង្កេតរាល់គ្រប់សកម្មភាពរវាងចិត្ត និងចិត្ត តើអាចបន្សាំស៊ីសង្វាក់ ឬចុះសម្រុងនឹងគ្នាដែរឬទេ...? សុភមង្គលប្រៀបដូចពន្លឺ

ភ្លើងទៀន...! បើយើងមិនចេះថែ វាអាចរលត់...! ចំពោះបងកុសល់ កូនសង្កេតឃើញថាគាត់ជាបុរសដែលកូនអាចផ្ញើវាសនាបាន...! ប៉ុន្តែដោយឡែក កូនសុំតាមដានគាត់បន្តបន្តិចសិន...! កូនមិនឱ្យពុក និងម៉ែពិបាកចិត្តរវាងកូន និងបងកុសលទេ...! សូមពុកនិងម៉ែជឿចុះថា កូនស្រីរបស់ម៉ែមិនទុំមុនស្រគាល មិនរំលងប្រពៃណី ឬធ្វើអ្វីៗឱ្យថ្លស់ផ្លោយចាកពីភាពបរិសុទ្ធឡើយ...! កូនខ្លាចណាស់ជីវិតដែលជួបស្នេហាបោកប្រាស ស្នេហាឆក់កណ្ដៀត ឬជួបជីវិតដែលខកបំណង អស់សង្ឃឹម...!

មីងលំអងខំញញឹមកាន់តែស្រស់ ដោយបន្សាត់សម្ដីជាចុងក្រោយ :

- ម៉ែ និងពុកខំសន្សំកុសលរាល់ថ្ងៃនេះ រំភើបហើយសប្បាយចិត្តណាស់ នៅពេលឮកូននិយាយបានពីរោះគ្បោះក្បាយយ៉ាងដូច្នេះ...! កូនស្រីពិតជាពេជ្រទាំងគ្រាប់សម្រាប់គ្រួសារយើងមែន...! ប៉ុណ្ណឹងចុះកូន...! កូនសម្រាកយកកម្លាំងចុះ...!

- សូមម៉ែថែសុខភាពផង...! សុខភាពល្អណាម៉ែ...! កូនសូមជម្រាបលា...!

ឆោមទេពីបិទទូរស័ព្ទ រួចបោះមកលើពូក ហើយផ្អៀងខ្លួនក្រាបលើគ្រែ ធ្វើឱ្យសំនុំសរសៃសក់ធ្លាក់រវេរវាយក្រាលរាយ ដូចធ្វើឱ្យនាងក្រមុំកាន់តែអន្ទះអន្ទែងនៅក្នុងផ្ចិតអារម្មណ៍ ដោយឮវាចារសាត់តិចៗ... " នៅពេលនេះ មានស្រមោលបុរសពីរនាក់តាមអន្ទោលក្នុងបេះដូងខ្ញុំ...! តើមានស្រមោលបុរសប៉ុន្មាននាក់ទៀតទៅ តាមទន្ទ្រានក្នុងដួងព្រលឹងខ្ញុំបន្តទៀត ចំពោះមាតិកាស្នេហាដ៏អាថ៌កំបាំងនេះ...? បេះដូងខ្ញុំសម្រាប់បុរសណាម្នាក់ទៅ ដែលមានវាសនាលើជីវិតខ្ញុំនោះ...? វាសនាមិនទៀង តែពេលនេះបេះដូងខ្ញុំមានពណ៌ិចម្រុះហើយ...! សុភមង្គល...! សេចក្ដីស្នេហា...! ឆាកជីវិត...! អ្វីៗសុទ្ធតែសាំញ៉ាំ ស្មុគស្មាញទាំងអស់...! " ។

ស្អែកឡើង... ប្រមាណម៉ោងប្រាំបីកន្លះព្រឹក... ក្រុមអ្នកទេសចរដើរពាក់ពពូនពេញទីប្រជុំជន ។ ខ្លះដើរទៅស្រស់ស្រូបអាហារ ។ ខ្លះដើរទិញផលាផលសម្រាប់ទុកទទួលទាននៅតាមផ្លូវ ។ អ្នកខ្លះទៀតដើរចូលហាងនានា ដើម្បីជាវវត្ថុអនុស្សាវរីយ៍សម្រាប់ទុកផ្ញើក្រុមញាតិនៅឯភ្នំពេញ ។ កុសលឈរគ្រេះគ្រុះក្បែររថយន្តនៅចំពីមុខហាង



មួយ ដែលមានអ្នកស្រីផល្គុន និងថាវរីកំពុងឈរលក់ដូរទាំងទឹកមុខស្រស់ស្រាយរួសរាយរាក់ទាក់ ដោយឃើញកញ្ញារ័តន៍ឈរអើតអើមតាមទូតាំងវត្ថុបុរាណទាំងឡាយហាក់ពេញចិត្តលើរូបចម្លាក់ទាំងនោះជាពន់ពេក ។

ថាវរីញាក់មុខដាក់ម្ដាយ ដោយបូញមាត់មកនាងក្រមុំ ធ្វើឱ្យអ្នកស្រីផល្គុនតាមសម្លឹង :

- អ្នកម៉ាក់...! បងស្រីនោះស្អាតសោភាខ្លាំងណាស់...! ស័ក្ដិសមជាក្រមុំភ្នំពេញមគ្គុទ្ទេសក៍រូបស្រស់មែន...! សូម្បីរូបសម្រស់កូន បើប្រៀបផ្ទឹមពុំអាចស្មើបានឡើយ...!

អ្នកស្រីកេះកូនស្រី ហើយឱននិយាយតិចៗ :

- ប្រហែលជានាងក្រមុំនោះទេដឹង ដែលកូនរក្សបាក់ចិត្តស្រឡាញ់ណាកូនរី...? អញ្ចឹង...! តស់... ទៅតាមម៉ាក់...!

អ្នកស្រីផល្គុនដឹកដៃថាវរីដើរសសៀរមកជិតឆោមស្រស់ ដោយបន្លឺវាចាមួយៗ :

- ក្មួយស្រីជាអ្នកនាំភ្ញៀវដើរជាវវត្ថុអនុស្សាវរីយ៍អ្វីក្មួយ...?

ស្រស់នរនាថសើចញឹមៗបង្ហើរសម្រស់ :

- ចាំសអ្នកស្រី...! ប្រសិនបើពួកនាងខ្ញុំជាវវត្ថុអនុស្សាវរីយ៍ តើអ្នកស្រីអាចចុះតម្លៃឱ្យប៉ុន្មានភាគរយដែរ...? ពួកនាងខ្ញុំជាវច្រើនណាស់...!

ថាវរីលួចក្ដាញ់តាមតយគន់ទាំងសើចកក្អៀក រួចលូកដៃមកក្បៀកដៃស្រស់ស្រីដោយធ្វើឫកជំទើតជំទូយញ៉េះញ៉ោះ :

- សម្ដីអ្នកបងស្រទន់ពេញទឹកដមខ្លាំងណាស់...! បើពួកអ្នកបងជាវច្រើន នាងខ្ញុំចុះតម្លៃឱ្យសាមសិបភាគរយ ហើយនាងខ្ញុំឱ្យលុយក្រៅជូនអ្នកបងម្ភៃភាគរយទៀតដែលអ្នកបងខំនាំភ្ញៀវមកជាវរបស់នៅហាងនាងខ្ញុំ...! អ្នកបងមាននាមប័ណ្ណទេ...?

កញ្ញារ័តន៍សើចប៉ប្រិម ហាក់សប្បាយចិត្តចំពោះខ្លួននាងដែលរកកម្រៃបានដោយងាយ ហើយនាងលើកកូនកាបូបស្ពាយមករូតបើក រួចទាញនាមប័ណ្ណមួយសន្លឹកហុចមកឱ្យថាវរី ទាំងស្រដីថ្នមសម្លេង :

- មាន...! នេះនាមប័ណ្ណរបស់ខ្ញុំ...!

ថាវីប្រឡេះដៃចេញពីដៃនាងក្រមុំ ហើយទទួលនាមប័ណ្ណលើកមកសម្លឹងដោយឧទាន :

- ញាណ កញ្ញាវ័តន៍...! ឈ្មោះអ្នកបងពីរោះណាស់...! ស័ក្តិសមនឹងរូបសម្បត្តិអ្នកបងមែន...!

បញ្ចប់សម្តីភ្លាម ថាវីហុចនាមប័ណ្ណមកឱ្យអ្នកស្រីជាម្តាយ ហើយបន្ថែមសម្តី :

- អ្នកម៉ាក់...! អ្នកបងឈ្មោះកញ្ញាវ័តន៍...! ឈ្មោះនេះពីរោះទេ អ្នកម៉ាក់...?

អ្នកស្រីផល្លុនបើកភ្នែកភ្ញាក់ផ្អើល ហើយសម្លឹងមកស្រស់តរុណីក្រោមក្រសៃភ្នែកយ៉ាងមុត រួចគិតព្រួចនៅក្នុងចិត្ត... " ពិតជាស្រស់ស្អាតគួរឱ្យសរសើរមែនហ្ន៎...! អញ្ចឹងទេតើ បានជាកូនរក្សប្រកាច់ប្រកិន ទន្ទេញឈ្មោះមិនឈប់...! បើរូបខ្ញុំបានរូបនាងធ្វើជាកូនប្រសា ប្រហែលជាពូកឧកញ៉ា សព្វមុខមន្ត្រីក្រោមឱវាទចាំវាពិតជាភ្ញាក់ផ្អើល ហើយជញ្ជក់មាត់លបលេបទឹកមាត់ អួតសរសើរពុំខាន...! កូនរក្សពិតជាភ្នែកមុតមែន អាកូនមាត់ដាច មាត់រអិលនេះ...! " ។

ថាវីកេះត្រគាកម្តាយដែលឈរស្ងួក កំពុងភ្លឹកភ្លាំងស្មារតី ធ្វើឱ្យស្ត្រីញញោចភ្នែកហើយសើចពព្រាយ :

- ចុំម...! យីកូននេះ ចេះកេះឯងឱ្យភ្ញាក់អញ្ចឹងកើតដែរ...! ( អ្នកស្រីធ្វើឫកជាសម្លក់មកកូនស្រី រួចបែរមកញញឹមប៉ប្រៃដាក់ឆោមស្រស់ ) បើក្មួយស្រីនាំភ្ញៀវម៉ោច្រើនអញ្ចឹង មីងថែមលុយធីបឱ្យក្មួយហាសិបភាគរយចុះ...! ថ្ងៃ១ក្រោយ បើម៉ោសៀមរាបទៀត ក្មួយស្រីអាចទៅស្នាក់ផ្ទះមីងក៏បាន...! មិនបាច់ទៅគេងផ្ទះសំណាក់ ឬអូតែលទេ នាំតែអស់សោហ៊ុយច្រើន...! មីងមាននិស្ស័យនឹងក្មួយស្រីខ្លាំងណាស់ក្មួយ...!

កញ្ញាវ័តន៍សើចញឹម១ តាមសម្លឹងក្រុមអ្នកទេសចរ កំពុងនាំគ្នាកាន់វត្ថុអនុស្សាវរីយ៍ទៅទូទាត់លុយគាក់ជាមួយបុគ្គលិកក្នុងហាង ដោយមានថាវីរ៉ំកិលជំហានទៅខ្សឹបប្រាប់អ្នកគិតលុយ រួចកាន់នាមប័ណ្ណមួយសន្លឹកត្រឡប់មកវិញ ទើបឆោមកល្យាណីបង្វែរសម្តីមកអ្នកស្រីផល្លុន :



- អរគុណអ្នកមីង...! សង្ឃឹមថា ក្មួយនឹងឧស្សាហ៍នាំភ្ញៀវមកសៀមរាបចុះ...! បើមានឱកាសនោះមែន ក្មួយនឹងទៅសម្រាកផ្ទះអ្នកមីង...!

ថាវីហុចនាមប័ណ្ណមកឱ្យនាងក្រមុំ ទាំងតោងចង្កេះ បង្កើនភាពស្និទ្ធស្នាល :

- នេះនាមប័ណ្ណនាងខ្ញុំ...! អ្នកបងឃើញស្រាប់ហើយ មានបញ្ជាក់ទាំងអាស័យដ្ឋានរបស់នាងខ្ញុំទៀតផង...! អ្នកបងគួរឱ្យស្រឡាញ់ខ្លាំងណាស់...!

- អរគុណហើយថាវី...!

កែវមាណវីនិយាយបណ្តើរ ភ្នែកសម្លឹងមកនាមប័ណ្ណរបស់ថាវីបណ្តើរ ហើយរេសម្លឹងទៅក្រុមអ្នកទេសចរ កំពុងនាំគ្នាយួរវត្ថុអនុស្សាវរីយ៍ចេញពីហាង ដោយដើរឡើងទៅលើរថយន្ត ដែលមានកុសលកំពុងបញ្ឆេះយានរង់ចាំ ។ អ្នកស្រីញញឹមដាក់ឆោមទេពីបន្តិច ទើបងាកទៅបុគ្គលិកដែលកំពុងគិតលុយ :

- យ៉ាងម៉េចហើយអាឡានី...? ទូទាត់សាច់ប្រាក់ឱ្យក្មួយស្រីហើយឬនៅ...?

- ចាំស រួចហើយអ្នកស្រី...!

ជម្រុះចម្លើយមកបណ្តើរ នាងគណនេយ្យកាន់សំបុត្រខ្ចប់សាច់ប្រាក់ ដើររលះរលាំងសំដៅមកបណ្តើរ ដោយហុចមកឱ្យអ្នកស្រីផល្លុន ទាំងឈរសើចញឹម១ :

- នេះអ្នកស្រី...! អ្នកនាងថាវី ឱ្យខ្ញុំបន្ថែមលុយខ្លះទៀតជូនអ្នកនាងខាងនេះ...!

អ្នកស្រីងក់ក្បាល ទំនងជារំភើបចិត្ត ដោយទទួលសំបុត្រខ្ចប់លុយហុចមកឱ្យកែវវ័តន៍នារី :

- នេះលុយធីប ដែលមីងបន្ថែមជូនក្មួយស្រី ទុកជាចំណងដៃអនុស្សាវរីយ៍...! ថ្ងៃក្រោយកុំភ្លេចមកលេងនឹងមីងផង...! ចុះក្មួយស្រី ទៅភ្នំពេញវិញអង្កាល់ដែរ...?

ស្រស់វិលក្ខណ៍លើកដៃទទួលសំបុត្រ ទាំងប្រណម្យក្នុងសភាពទន់ភ្លន់ :

- អរគុណអ្នកមីង...! អរគុណនាងអូនថាវី...! ចាំស... ប្រហែល... មិនដឹងទេអ្នកមីង...!

ខណៈនោះ សម្លេងស៊ីប្លេយានក៏លាន់ទីន១ ដែលកុសលចុចបន្ទីហៅយ៉ាងញាប់រន្ទើន ធ្វើឱ្យស្រស់ទងវង់រុញសំបុត្រចូលក្នុងកាបូប ដោយងាកទៅសម្លឹងរថយន្តកំពុងរំកិលទៅមុខសន្សឹម១ ហើយងាកមកបន្ទន់ខ្លួនដាក់ម្ចាស់ហាង :

- នាងខ្ញុំសូមជម្រាបលាសិនហើយ...! ថ្ងៃក្រោយជួបគ្នាទៀត...!

វលាស់សម្លេងបញ្ចប់ភ្លាម កែវកញ្ញារ័តន៍ក៏ដើរចាត់រញ៉ាត់ចេញទៅក្រៅ ទាំងបម្រុងនឹងបើកទ្វារហាង ក៏ស្របគ្នានឹងថាវរៈរុញបន្ទះទ្វារដើរចូល ធ្វើឱ្យប៉ះខ្លួននាងក្រមុំឱ្យទ្រេតទៅក្រោយមួយជំហាន រួចឈរស្រឡាំងកាំង :

- ហ៊ាក...! កញ្ញារ័តន៍ទេ...? ខ្ញុំ... ខ្ញុំសុំទោស...!

ស្រស់នវនាថក្តាប់មាត់សម្លក់ ហាក់គ្រីតក្តាញ់ :

- កម្លោះថ្លើមយោល..! កម្លោះមាត់ប្រហុក...! តាមនិន្នាឱ្យគ្រប់កន្លែងតែម្តង..!

អ្នកកម្លោះធ្វើភ្នែកស្លឹ មើលទៅអ្នកម្តាយ និងប្អូនស្រីកំពុងនាំគ្នាខ្ទប់មាត់សើច ហើយស្រស់តូចតន់ ក៏ច្រានទ្រូងនរៈយ៉ាងអស់ទំហឹងឱ្យទ្រេតផ្ទឹបទៅជញ្ជាំងម្ខាង ទាំងបោះសម្តី :

- កុំប៉ិនដើរតាម មើលតែខ្មោចតាមទារពៃពេក កម្លោះខ្មៅសម្ញេញ មុខមើលតែអាពីង...!

កញ្ញារ័តន៍បើកទ្វារហាងដើរលឿនស្លៅឡើងទៅលើរថយន្ត ធ្វើឱ្យលិខិតដែលទើបនឹងងើបដើរចេញពីរថយន្ត ក៏បើកភ្នែកធំគ្រលួង :

- ពិតជានាងកញ្ញា ឈ្មោះកញ្ញារ័តន៍នោះហើយ...! ស្អាតផស់គេមែនវ៉ើយ...! ស្អាតមែនហ្ន៎...!

រថយន្តលូនទៅមុខឃឹត១ កញ្ញារ័តន៍ទាញទ្វារបិទទាំងធ្វើមុខក្រញូវ ហើយក្រឡេកមើលទៅខាងមុខហាង ឃើញថាវរៈទាញទោចក្រយានដែលជាតួកង់ប្រុស បង្ខិលហើយលោតឡើងជិះដោយប្រឹងធាក់ឈ្នាន់ ក៏របូតច្រវាក់ ធ្វើឱ្យលិខិត អ្នកស្រីផល្គុនថាវីរ៍ និងបុគ្គលិកក្នុងហាងនាំគ្នាឈរសើច ហើយទះដៃហ៊ោកេ្រវ១ ។



ស្រស់ស្រីសម្តីស្រទន់ខាំមាត់ពេប ដោយគិតកូចរាយមាយ... សម័យទំនើបទៅហើយ នៅជិះកង់ធ្លាក់ច្រវាក់ទៀត...! ចំជាដាច់យ៉ៃសែនដាច់ដាប មើលតែអាបតាមស៊ីជ្រាំមែន...! ឡឹកីមើលតែមនុស្សឆ្កួតអញ្ចឹង ក៏ប្រឹងអួតឱ្យវឡបកើតដែរ...! ជ្រេញណាស់ កម្លោះមុខសំពោច មហាសំពឹកនេះ...! ។

កុសលកំពុងបញ្ជាយាន បែរមកសម្លឹងនាងក្រមុំដែលកំពុងឈរតាមសម្លឹងសកម្មភាពថាវរៈ ដោយជម្រុះសម្លេងមួហ្មង ទាំងធ្វើមុខស្មឿក :

- នៅឈរច្រិមច្រុមដល់ណាទៀត...! ម៉េចក៏មិនអង្គុយចុះម៉ោ...! ល្ងីល្ងើមើលតែល្ងលីងជ្រុល...!

ឆោមល្អសើចញឹម១ រំកិលជំហានមកទម្លាក់បង្គុយក្បែរកុសល ហើយលើកដៃទះស្មាតែកុងឡានកម្លោះ :

- មិនដឹងជាស្អីទេបងកុសល...! ប្រៀបធៀបអូនទៅនឹងល្ងលីងខ្លោចទៅវិញ...! ម៉េចឆ្មៀមចិត្តលែងឆ្ងាញ់អ្វីបង...?

កុសលគ្រវីក្បាលដូចមិនយល់សម្តីស្រស់នវនាថ រួចក៏ផ្ទុះសំណើចទាំងញាក់ស្មា ធ្វើឱ្យក្រុមអ្នកទេសចរ ក៏សើចអាករអាយជាមួយដែរ ។ កញ្ញារ័តន៍ក៏សើចកក្អៀក រួចចាប់ញ៉ឹងត្រចៀកកុសលគ្រវីតិច១ ។

យានទេសចរចេះតែចររំកិលទៅមុខ ដោយបើកតម្រង់ទៅទិសខាងជើងក្រុងសៀមរាប រួចបត់មកទិសខាងលិច កាត់ខាងមុខប្រាង្គប្រាសាទអង្គរតូច ហើយបត់ទៅទិសខាងជើងបន្ត ឆ្លងកាត់ខ្លោងទ្វារអង្គរធំ ទើបរថយន្តឈប់សំចតស្ងៀមទ្រឹងក្នុងបរិវេណប្រាង្គប្រាសាទបាយ័ន ។

ក្រុមអ្នកទេសចរក៏ប្រញាប់គ្នាចុះចាកពីរថយន្ត ហើយក្រឡេកមើលក្រុមអ្នកទេសចរបរទេសឯទៀត កំពុងបណ្តើរគ្នាជាក្រុម១សំដៅទៅប្រាសាទបាយ័ន ។ កញ្ញារ័តន៍ដើរចុះមកខាងមុខក្រុមអ្នកទេសចរដោយសើចញឹម១ ហើយកុសលក៏ដើរមកឈរក្បែរ ។ នាងក្រមុំឈរនិយាយទាំងធ្វើកាយវិការបណ្តាលឱ្យក្រុមអ្នកទេសចរឈររហង់រង់ចាំស្តាប់ :

- តាមឯកសាររបស់លោក ហ៊្សេក សេដែស ជាចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេសបាននិយាយអំពី " ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ " ដោយបានបកស្រាយថា ប្រាសាទបាយ័ននៃអង្គរធំ ជាប្រាសាទមានអាថិកំបាំង ដែលបានចោទបញ្ហាជាច្រើនចំពោះបុរាណវិទូ...! បុរាណវិទូជាច្រើននាក់ តែងសរសើរដល់មហាស្ថាបត្យកម្មនេះ...! អ្នកខ្លះថា ប្រាសាទបាយ័នជាស្ថាបត្យកម្មអច្ឆរិយៈចំណាត់ថ្នាក់លេខមួយ ហើយប្រាសាទនេះ ផ្តល់ដល់ខ្សែចក្ខុយើងនូវការពិតដ៏ចម្លែកក្រៃលែង...! អ្នកខ្លះថា ប្រាសាទបាយ័ន ជាសំណង់ទេពនិទាន និងជាសំណង់ដែលល្អចម្លែកជាងសំណង់ប្រាសាទទាំងអស់ដែលបុព្វបុរសខ្មែរបានបន្សល់ទុក...! អ្នកខ្លះក៏លាន់មាត់ហើយស្រដីថា ខ្ញុំងើបក្បាលមើលទៅប្រាង្គទាំងឡាយ ដែលរត់ត្រង់ជួរដូចបន្ទាត់ មានពណ៌បៃតងស្រស់ និងខ្ញុំភ័យរន្ធត់ភ្លាម មិនដឹងជាមូលហេតុអ្វី ពេលឃើញស្នាមញញឹមពីលើកំពូលប្រាង្គធ្លាក់មកលើខ្ញុំ និងបន្ទាប់មក មានស្នាមញញឹមទីបី ទីបួន ទីប្រាំ ទីដប់ និងគ្រប់ទីកន្លែងទាំងអស់ និងខ្ញុំត្រូវស្នាមញញឹមទាំងនោះតាមគ្រប់កន្លែង...!

ក្រុមអ្នកទេសចររំភើបចិត្ត កាលបើបានស្តាប់សំនួនវោហារនាងក្រមុំខំបកស្រាយតាមឯកសារច្បាស់លាស់ ធ្វើឱ្យបងស្រីម្នាក់កំពុងពកូន ក៏អន្ទោកអន្ទោលបន្តទៀត :

- ប្រាសាទបាយ័នមានអានុភាពខ្លាំងក្លា និងជាប្រលោមនិយមពិសេសអស្ចារ្យ...! នាងអូនបន្តទៀតទៅ ពួកយើងរំភើបចិត្តណាស់ នៅពេលបានឃើញប្រាសាទដ៏ធំស្កឹមស្កៃអញ្ចឹង...!

- បុព្វបុរសខ្មែរ ពិតជាបានបន្សល់ទុកកេរដំណែលដ៏បវររាប់រយតំណមែន...! អ្នកខ្លះក៏បានស្បថស្បែសច្ចាថា មុននឹងស្លាប់ សុំជួបអង្គរ...! អ្នកខ្លះមួយជីវិតមិនស្គាល់អង្គរ ហើយស្លាប់ទៅទាំងនៅសោកស្តាយ...! ក្មួយស្រីបន្តទៀតចុះ អ៊ំចាំស្តាប់ការបកស្រាយរបស់ក្មួយ...!

អ៊ំប្រុសអូសដៃភរិយាមកឈរកៀ្បរស្រស់កញ្ញារ័តន៍ ដែលកំពុងលើកដបទឹកបរិសុទ្ធមកក្រេបក្តិក១ជួយផ្សើមបំពង់ក រួចក៏សើចបំប្រិម ទាំងកាន់ដៃកុសលលញ់អង្អែល



ថើ១ :

- មានអ្នកបុរាណវិទូខ្លះ ក៏ស្ងើចសរសើរពីសំណង់ដ៏ធំមហិមានេះដែរ ដោយពួកគេនិយាយថា សំណង់ធំស្កឹមស្កៃនេះ បង្ហាញនូវទិដ្ឋភាពថ្មធ្លាក់ដូចជាកំពូលភ្នំធ្លាក់ និងធ្វើដោយស្នាដៃមនុស្ស...! បើយើងដើរកម្សាន្តនៅពេលយប់ មានព្រះចន្ទ្រពេញបូរមីណ៍នៃរាត្រីកាល ដែលមេឃស្រឡះគ្មានពពកនោះ យើងនឹងមានមនោសញ្ចេតនា ដូចកំពុងដើរទស្សនាប្រាសាទនៅពិភពមួយផ្សេងទៀត គឺជាប្រាសាទដែលស្ថាបនាដោយស្នាដៃមនុស្សពិត១...! អ្នកខ្លះទៀតបានសរសេរថា នៅលើមេឃដ៏ខ្ពស់ ព្រះភក្ត្រទាំងបួននៃរូបចម្លាក់មុខព្រហ្មនេះ មាននៅគ្រប់កំពូលប្រាង្គសម្លឹងមើលទៅទិសទាំងបួន ដោយការញញឹមក្រោមច្រមុះត្រង់ និងរក្សាត្របកភ្នែកបិទពាក់កណ្តាលដូច១គ្នា ហើយព្រះភក្ត្រទាំងនេះបង្ហាញនូវព្រះវត្តមានគ្រប់ទីកន្លែងនៃអាទិទេពអង្គរ...! ដូច្នេះ យើងនាំគ្នាទៅទស្សនារូបចម្លាក់នានានៅតាមថែវគ្រប់ជញ្ជាំង ឱ្យរឹតតែយល់ ឱ្យកាន់តែពិស្តារ...! អញ្ជើញដើរទស្សនា ឱ្យសប្បាយណាបងប្អូន...!

រំពេចនោះ សម្លេងមួយរសាត់មកពីខាងក្រោយខ្នងក្រុមអ្នកទេសចរ លាយសំណើចតិច១ :

- ពិតជាបានសំនួនវោហារមែនហ្ន៎...! អ្នកចេះប្រើមាត់ អ្នកល្ងង់ប្រើដៃ ឬក៏អាចថាបាន អ្នកចេះប្រើកម្លាំងប្រាជ្ញា រីឯអ្នកល្ងង់ប្រើកម្លាំងបាយ...! ស័ក្តិសមជាមគ្គុទ្ទេសក៍ក្រមុំ ឈ្មោះកញ្ញារ័តន៍មែន...!

កុសល កញ្ញារ័តន៍ និងក្រុមអ្នកទេសចរបំបែរខ្លួនសម្លឹងទៅប្រភពសម្តី ក៏បានយល់ថាវរៈបណ្តើរកង់ចូលមក ដោយបែកញើសតយៀវ ធ្វើឱ្យនាងក្រមុំខាំមាត់សម្លក់ :

- នែ៎លោក...! លោកឯងចង់យ៉ាងម៉េចហ្នឹង បានជាខំម៉ោតាមខ្ញុំដូចរុយក្បាលខៀវអញ្ចឹង...? ( ស្រស់នរនាថជះសំណួរដាក់ថាវរៈរួច ក៏បែរមកនិយាយជាមួយក្រុមអ្នកទេសចរ ) សូមបងប្អូនទាំងអស់ អញ្ជើញទៅទស្សនាប្រាសាទបាយ័នចុះ...! ខ្ញុំ... ខ្ញុំចង់ប្រដៅលោកអាពីងនេះបន្តិចសិន...!

អ្នកទេសចរទាំងអស់ហ៊ោក្រវទះដៃប្រាវ រួចនាំគ្នាដើរចេញ ធ្វើឱ្យថាវរៈដាក់ចន្ទល់កង់ ហើយឈរញាក់ចង្កេះ :

- យី... លោកអាពីង...? ឈ្មោះបងគឺថាវរៈទេតើ...!

- ចុះខ្ញុំមានសួរឈ្មោះលោកឯងឯណា...! ម៉េចក៏ប្រាប់...? យ៉ាប់មែនទែនលោកឯងនេះ...! សម្បុរខ្មៅក្រិតដូចអាពីងអញ្ចឹង ចេះមានឈ្មោះថាវរៈកើតដែរ...!

ឆោមល្អថាហើយ ក៏អូសដៃបានថយក្រោយ បម្រុងបង្វែរខ្លួនដើរទៅតាមក្រុមអ្នកទេសចរ ធ្វើឱ្យអ្នកកម្លោះមាត់ដាច ញោចស្មាដើរតឃ្លើនមកក្បែរ :

- អត់ដឹងថា សត្វអាពីងដល់ពេលបំពងទៅ វាឆ្ងាញ់ត្រង់ណាទេអ្ហ៎...? អាពីងឆ្ងាញ់ត្រង់ព្រះកន្ទីង ដែលពេញខ្ទិះនោះអី...! ព្រះកន្ទីងធីងអើយ អីក៏ឆ្ងាញ់ហើយឈ្ងុយយ៉ាងហ្នឹង...!

កុសលស្ទុះហេទៅក្របួចកអាវថាវរៈ ហើយក្តាប់ដៃលើកឡើងបម្រុងដាល់ ដោយសង្រ្កឹតធ្មេញ ដំឡើងមុខដូចរាហ៍ :

- មាត់កុំអត់គម្របខ្លាំងពេក...! តិចបាក់ធ្មេញទាំងក្រាសឥឡូវ...! អាម្សៀឯងហ្នឹង យើងខាំមាត់សង្កត់ចិត្តយូរហើយ...! ច្រឡឹមខុសបទ មិនសមខ្លួនជាប្រុសទេ...!

ថាវរៈញាក់ស្មា ហាក់មិនតក់ស្លុតនឹងការគម្រាមកំហែងពីសំណាក់កុសល :

- កុំថាឡើយបាក់ធ្មេញទាំងក្រាស សូម្បីតែខ្សែវភ្នែក ហើយវៀចថ្គាមទៀតក៏យើងអត់ញញើតដែរ..! ម៉េចភ្លើងប្រច័ណ្ឌវាដុតរោលខ្លាំងណាស់អ្ហ៎ លោកតែកុងឡាន..?

កុសលក្តាប់ដៃឡើងញ័រទទ្រើត ហើយផ្ទៃមុខក៏ក្រហមដូចរងើកភ្លើង :

- បែកកញ្ចប់មាត់ឥឡូវ...! ទោះបីជាកូនលោកកុងស៊ុយក៏យើងមិនខ្លាចដែរ...!

កញ្ញារ័តន៍ស្ទុះមកទាញដៃកុសល ទាំងស្វាយបបូរមាត់ :

- បងកុសល...! កុំណា...! ប៉ុណ្ណឹងបានហើយ...!

កុសលទម្លាក់ដៃចុះ ហើយយកប្រអប់ដៃមកជូតត្រដុសលើគូថខោ រួចរលាស់ដៃ បោះជំហានទៅកាន់រថយន្ត ទាំងបង្ហើរសម្តី :



- អាផេះ...! មុខដូចអាញីត្រាំស្រាអញ្ចឹង ក៏ប្រឹងតាមញ៉ែឱ្យត្របែកើតដែរ...!

តែកុងឡានចិត្តភ្លើងឡើងទៅអង្គុយសម្ងំក្នុងរថយន្ត ហាក់ឈឺចុកចាប់ពើតផ្សានៅក្នុងចិត្តយ៉ាងឥតគណនា ។ ថាវរៈឈរធ្វើមុខស្រមែះ សម្លឹងមកស្រស់ស្រីដែលកំពុងបោះជំហានដើរចេញ ក៏លេចនាយសូ នាយគាំ នាយត្រាវ និងនាយមន ដែលជាសហការីដ៏ជំនិតក្រោមឱវាទខ្លួន រត់ត្រហេបត្រហបត្របាញ់កែងចូលមក ហើយនាយទាំងបួនភ្ញាក់ផ្អើលក្នុងចិត្តមិនតិចឡើយ នៅពេលឃើញរូបសម្រស់របស់មគ្គុទ្ទេសក៍ក្រមុំ ។

ថាវរៈជាបណ្ឌិតស្ថាបត្យកម្ម ដែលបានបញ្ចប់ការសិក្សានៅប្រទេសបារាំង ទីក្រុងប៉ារីស អស់រយៈពេលបីឆ្នាំមកហើយ។នរៈក៏ជាប្រធានផ្នែកគ្រប់គ្រងនៃការថែរក្សាកេតនភណ្ឌជាតិ និងជួសជុលរាល់គ្រប់ប្រាង្គប្រាសាទនានានៅតំបន់អង្គរ ។ សព្វថ្ងៃនេះអ្នកកម្លោះ និងសហការីទាំងបួននេះ ក៏បានកំពុងជួសជុលកែលំអប្រាសាទបាយ័ន នៅថែវម្ខាងនាជ្រុងខាងជើង ដោយសហការជាមួយអង្គការមួយ ។ ប៉ុន្តែជានិច្ចកាល អ្នកកម្លោះឧស្សាហ៍ឡើងចុះភ្នំពេញដើម្បីប្រជុំ រៀបចំគម្រោង និងកិច្ចការដ៏ទៃទៀត ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ក្រុងអង្គរ ។

នរៈសើចស្ងេញ ទាំងងាកមុខមកពេបមាត់ដាក់កុសលកំពុងអង្គុយក្នុងរថយន្តបានសម្លឹងមក រួចក៏សើចញីម១ដាក់នាយទាំងបួន ទាំងមិនចេញស្តី ហើយក៏បោះជំហានដើរនាំមុខសហការីតម្រង់ទៅប្រាសាទបាយ័ន ដោយឃើញរ័តន៍នារីកំពុងឈរពន្យល់ក្រុមអ្នកទេសចរនៅតាមជញ្ជាំងម្ខាង ។ នៅពេលឃើញថាវរៈដើរនាំមុខកូនចៅទាំងបួនភ្លាម កញ្ញារ័តន៍មូរមុខចងចញ្ចើម ក៏សសៀរផ្តាច់ខ្លួនចេញពីក្រុមអ្នកទេសចរ ហើយស្រូតជំហានដើរឡើងទៅទស្សនារូបចម្លាក់ព្រះភក្ត្រព្រះព្រហ្មនៅជាន់ប្រាង្គខាងលើ ទាំងមិនសប្បាយចិត្ត ។

លុះឡើងមកដល់តួប្រាង្គខ្ពស់ ឆោមឆវីក៏ក្រឡេកមើលទៅបន្ទប់ល្ហាងមួយនោះ ក៏បានប្រទះឃើញអ្នកកម្លោះរូបស្រស់ម្នាក់ទៀត មានសម្បុរខ្មៅស្រអែមស្រស់ សក់រួញទីករលក ស្មាក្រាស់ធំមាំ ហើយមានផ្ទៃមុខស្រស់សមឥតខ្ចោះ ដូចទេវបុត្រមកក្រសាល

ប្រាង្គវិមាន ។ អ្នកកម្លោះរូបនេះឈ្មោះ "**ភូសា**" ជាអាណិកជនខ្មែរនៅសហរដ្ឋអាមេរិច ។ ភូសាកំពុងអង្គុយចាក់គម្ពីរនៅក្បែរលោកតាអាចារ្យម្នាក់ ដែលកំពុងធ្វើកាយវិការពន្យល់រៀបរាប់តាមក្បួនតម្រាក្នុងគម្ពីរ ។

បន្ទាប់មកឃើញនរៈអាណិកជនលើកគម្ពីរមកដាក់លើក្បាល ហើយលើកកូនឈើចាក់ចូលគម្ពីរ ទាំងកែវភ្នែករវេសម្លឹងមកនាងក្រមុំកំពុងឈរអើតអើមសម្លឹងមកដែរ ។ ពន្លឺចក្ខុបានប្រទាក់គ្នាយ៉ាងរហ័សដូចកាំរន្ទះ ធ្វើឱ្យឆោមនារីដកខ្លួនថយគេចមុខចេញ ទាំងឈរអល់អែករិះគិត... "ពន្លឺភ្នែកបុរសនេះម្ដេចក៏មានអានុភាពខ្លាំងម្ល៉េះ..! បេះដូងខ្ញុំឈឺឆៀប១ដូចជាសង្កៀររមាស់ ហើយព្រឺស្រៀវពេញរាងកាយ...! បុរសម្នាក់ហ្នឹង ពិតជាពេញអង្គជាមហាបុរសខ្មែរមែន...! ប៉ុន្តែ កូនប្រុសឱ្យត្រឡាំងទៅហើយ ម្ដេចក៏នៅតែជឿលើអបិយជំនឿទៀតអញ្ចឹង..? តិចលោកំពុងអង្គុយចាក់គម្ពីរផ្សងរកគូព្រេងទេដឹង..? ប្រុសសម័យទំនើប នៅជឿលើព្រេងវាសនាកើតដែរ...! ខ្ញុំចង់តែសើចឱ្យរយះមាត់ទេ...!" ។

ស្រស់ស្រីតូចតន់ខ្ទប់មាត់សើច ហើយអូសជើងអង្គីលថយក្រោយ ក៏ក្រឡាច់កជើងបម្រុងដួលទាំងជំហាររមៀលធ្លាក់ទៅក្រោមទៅហើយ ក៏ស្របពេលកម្លោះភូសាមើលឃើញទាន់ ក៏គ្រវែងគម្ពីរចោល ហើយលោតដោលមកត្រកងប្រាណឆោមល្អយ៉ាងរហ័សទាំងស្រែកខ្ទ័រស្ទើរធ្លាក់កន្ទើត :

- ប្រយ័ត្ន...! អ្នកនាងប្រយ័ត្នធ្លាក់...!

តាអាចារ្យស្ទុះចេញមកឈរក្បែរ ហើយលោដៃម្ខាងទៅស្រវាចាប់ដៃនាងក្រមុំនៅពេលភូសាលើកត្រកងឱ្យទប់ជំហារតាមសម្រួល :

- ចៅស្រី អត់អីទេអ្ហ...? ចុះកជើង មានគ្រិចថ្លស់ទេចៅស្រី...?

- ចាំស អត់ទេលោកតា...! អរគុណពូហើយ...! ខ្ញុំសូមអរគុណពូ...!

ស្រស់មាណវីឈរឃ្វើចជើង រាងទន់ផ្សៀងខ្លួន ធ្វើឱ្យភូសាអង្គុយចុះ ហើយសម្លឹងមកកជើងស្រស់ស្រីទាំងស្រដី :

- កជើងអ្នកនាងប្រហែលជាគ្រិចទេដឹង បានជាឈរខ្វូច១អញ្ចឹង...? បើថ្លស់មែន



ខ្ញុំជួយរីតច្របាច់ឱ្យ...! កុំអៀនធ្វើអី យើងជួយគ្នាក្នុងគ្រាមានអាសន្នអញ្ចឹងហើយ...!

ឆោមតរុណីបម្រុងប្រកែកដោះសា មិនឱ្យភូសាជួយរីតច្របាច់សរសៃកជើង ក៏ងាកទៅឃើញថាវរៈ និងសហការីទាំងបួនឈរមើងមាំងទាំងធ្វើមុខក្រញូវ ទើបនាងក្រមុំធ្វើឫកជាលើកជើង ដោយសម្ដែងភាពឈឺចាប់ :

- ពូជួយរីតបន្ដិចក៏បាន...! ខ្ញុំ... ខ្ញុំប្រហែលជាថ្លស់សរសៃកជើងមែនហើយពូ...!

ភូសាចាប់ច្របាច់រីតកជើងស្រស់នរនាថថ្នម១ ទាំងសើចញឹម១ហាក់ត្រឹតត្រាញ់ក្នុងចិត្តជាពន់ពេក ។ ថាវរៈវិញក្ដៅឆួល ស្ទើរស្រក់ឈាមហើយរអ៊ូ... "យ៉ើ...! មានអាកម្លោះខ្មៅគម្រាំងចែត សក់ក្រញាញ់ដូចត្នោតរន្ទះបាញ់ម្នាក់ទៀតហើយវ៉ើយ មកជ្រៀដណ្ដើមស្រីពីយើង...! ហ៊ឺះ អាអន្ទិតមុខយ៉ាប់ឯងហ្នឹង កុំសង្ឃឹមថាបានកញ្ញារ័តន៍ធ្វើជាគូនោះ...! យើងដាច់ខាតមិនឱ្យរូបនាងទៅសម្ងំសោយសុខ ក្រោមលង្វែកទ្រូងឯងបានយ៉ាងងាយឡើយ...! អូនកញ្ញារ័តន៍ ជាកម្មសិទ្ធិផ្ដាច់មុខរបស់យើងមួយរយភាគរយនៅជាតិនេះ...! មើល៍១ ហ៊ានលញ់អង្អែលសាច់ម្ចាស់បេះដូងយើង គ្មានកោតក្រែងចិត្តយើងបន្ដិចណាសោះ...! ឯងនេះថ្លើមធំមែន...!" ។

សហការីទាំងបួនមើលមុខគ្នាឡិនឡង់ ហើយខ្ទប់មាត់សើចដោយបែរមុខចេញ ។

Khmer Story Lovers